**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Universite´ Royale de Droit et des Sciencess Economiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការលុបចោលកិច្ចសន្យា

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **អ៊ុំ ណារិទ្ធិ**

សាស្ត្រាចារ្យណែនាំ

**លោកស្រី ទី សុឃីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំចូលសិក្សា ២០១៧

ជំនាន់ទី ២១

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ អ៊ុំ ណារិទ្ធិ ជានិស្សិតថ្នាក់បរិញ្ញាបត្រឆ្នាំទី៤ ជំនាន់ទី២១ ក្នុងឆ្នាំសិក្សា ២០២០-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានសរសេរសារណានៅក្នុងគោលបំណងដើម្បីការពារបញ្ចប់សារណា ក្រោមប្រធានបទស្តីពី "ការលុបចោលកិច្ចសន្យា"។

ជាដំបូងខ្ញុំបាទ សូមថ្លែងអំណរគុណលំអោនកាយវាចាចិត្ត និងសម្តែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក **អ៊ុំ សុឃន** និងអ្នកម្តាយ **សុខ សុធារ៉ា**

លោកអ្នកមានគុណដែលបានផ្តល់កំណើតដល់កូន ដោយសេចក្តីស្រលាញ់ អាណិត និង តស៊ូចិញ្ចឹមបីបាច់ថែរក្សា អប់រំកូនឲ្យក្លាយទៅជាកូនល្អ ជាពលរដ្ឋល្អ សិស្សល្អ ព្រមទាំងបានឧបត្ថម្ភ និងជួយជាកម្លាំងចិត្តជម្រុញឲ្យកូនបានសិក្សា តាំងពីនៅបឋមរហូតមកដល់មហាវិទ្យាល័យ និងមកដល់សព្វថ្ងៃនេះ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ និងសាស្ត្រចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់** ដែលបានខិតខំអស់ពីសមត្ថភាពក្នុងការផ្ទេរនូវចំពោះដឹងយ៉ាងច្រើនមកឲ្យខ្ញុំបាទក្នុងរយៈពេល ៤(បួនឆ្នាំ) កន្លងមកនេះ ជាពិសេសខ្ញុំបាទក៏ទទួលបាននូវការតម្រង់ទិសពីសំណាក់លោកគ្រូ អ្នកគ្រូដែលធ្វើឲ្យខ្ញុំបាទបានក្លាយជាពលរដ្ឋល្អនៅក្នុងសង្គម។

ជាពិសេសជាងទៅទៀត ខ្ញុំបាទសូមថ្លែងអំណរគុណដល់អ្នកគ្រូសាស្ត្រចារ្យ **ឌី សុឃីតា** ដែលមិនត្រឹមតែបានបង្ហាត់បង្រៀនខ្ញុំបាទទេ ថែមទាំងបានណែនាំដល់ខ្ញុំបាទក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ និងបានចំណាយពេលវេលាមានតម្លៃ ផ្តល់ជាមតិយោបល់ ដ៏ដូចជាកែសម្រួលនូវចំណុចខ្វះខាត ក្នុងការចងក្រងបង្កើតជាសារណាមួយក្បាលនេះ។

ជាទីបញ្ចប់ខ្ញុំបាទ សូមគោរពជូនពរដល់លោកអ្នកមានគុណទាំងពីរ **ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តរួមថ្នាក់ មិត្តរួមជំនាន់** ទាំងអស់ សូមឲ្យជួបតែសេចក្តីសុខសុភមង្គល សុខភាពល្អបរិបូណ៌បានសម្រេចគ្រប់ភារៈកិច្ចនៃការងារ នឹងគ្រប់គោលបំណងដែលប៉ងប្រាថ្នា និងសូមជួបនូវពុទ្ធពរទាំងឡាយ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សៀវភៅសារណាស្តីពី "**ការលុបចោលកិច្ចសន្យា**" ដែលបានតាក់តែងឡើងនេះ ដើម្បីជាជំនួយដល់ការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត និងដល់ប្រជាពលរដ្ឋទាំងអស់ ដែលមានការចាប់អារម្មណ៍ទាក់ទងនឹងការលុបចោលកិច្ចសន្យា ពីព្រោះសៀវភៅមួយនេះ ជាប់ពាក់ព័ន្ធយ៉ាងជិតស្និតទៅនឹងសិទ្ធិ កាតព្វកិច្ច ដែលប្រើប្រាស់ក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសព្វថ្ងៃ។ ម្យ៉ាងវិញទៀត សារណានេះ ខ្ញុំបាទបានស្វះស្វែងរកឯកសារជាច្រើនដែលជាប់ទាក់ទងនឹងការលុបចោលកិច្ចសន្យា ដើម្បីបញ្ចូលនៅក្នុងខ្លឹមផ្សាសារណាមួយនេះ ទាំងខ្លឹមសារនៃបទបញ្ញត្តិច្បាប់ និងបទដ្ឋានគតិយុត្តជាច្រើនទៀតដែលបានចូលជាធរមាន និងកំពុងអនុវត្តសព្វថ្ងៃនេះ ដើម្បីឲ្យសារណានេះមានភាពច្បាស់លាស់ត្រឹមត្រូវតាមច្បាប់ និងដើម្បីជាភាពងាយស្រួលដល់មិត្តអ្នកអានទាំងអស់ យកទៅសិក្សាបន្ត។

សៀវភៅសារណានេះ គឺជាសមិទ្ធិផលដំបូងរបស់ខ្ញុំបាទដែលកើតចេញពីការខិតខំប្រឹងប្រែងរៀនសូត្ររបស់ខ្ញុំបាទអស់រយៈ៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ទើបធ្វើឲ្យខ្ញុំបាទមានសមត្ថភាពសរសេរសៀវភៅសារណានេះលេចចេញជារូបរាងឡើង បើទោះបីជាសៀវភៅសារណានេះបានលេចចេញជារូបរាងក៏ដោយ ក៏ខ្ញុំបាទដឹងថា សៀវភៅសារណានេះ អាចនឹងនៅមានកំហុស និងចំណុចខ្វះខាតជាច្រើន ពីព្រោះតែខ្ញុំបាទគ្រាន់តែជានិស្សិត ដែលទើបនឹងបញ្ចប់បរិញ្ញាបត្រ មិនទាន់មានចំណេះដឹងខ្លាំងក្លា គ្មានបទពិសោធន៍ក្នុងការតាក់តែងសៀវភៅបែបនេះពីមុនមក និងមិនមានបទពិសោធន៍ធ្វើការងារ ឬ អនុវត្តផ្ទាល់ក្នុងអនុវត្តន៍ ឬចូលរួមអនុវត្តន៍ការលុបចោលកិច្ចសន្យាដោយផ្ទាល់ឡើយ។ ហើយសៀវភៅនេះខ្ញុំបាទសង្ឃឹមថានឹងបានរួមចំណែកក្នុងការបង្ហាញផ្លូវខ្លះៗ ក្នុងការសិក្សារបស់មិត្តនិស្សិត និងអ្នកអានគ្រប់រូប ខ្ញុំបាទបានរៀបរៀងសៀវភៅនេះឡើង យល់ឃើញថា នូវមានការខ្វះខាតជាច្រើន ទាំងអក្ខរាវិរុទ្ធ ពាក្យពេជ្ជ និងការរចនាផងដែរនោះ។

ដូច្នេះសូមបណ្តាអ្នកអាន និងមិត្តនិស្សិតទាំងអស់មានការខន្តី អធ្យាស្រ័យដល់កំហុសខុសឆ្គងដោយអចេតនាទាំងឡាយដោយប្រការណាមួយរបស់ខ្ញុំបាទ។

ជាចុងក្រោយខ្ញុំបាទសូមស្វាគមន៍ដោយចិត្តស្មោះនូវរាល់មតិរិះគន់ ដើម្បីស្ថាបនាកែលំអរអំពីមិត្តអ្នកអានទាំងអស់គ្នា និងសូមអរគុណនូវទឹកចិត្តអ្នកអានគ្រប់ៗគ្នា ដែលបានអានសៀវភៅសារណារបស់ខ្ញុំបាទដោយយកចិត្តទុកដាក់។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................................ ១

**ជំពូកទី១**

**លក្ខខណ្ឌនៃការលុបចោលកិច្ចសន្យា**

**១.១.អត្ថន័យនៃការលុបចោលកិច្ចសន្យា** ........................................ ៣

**១.២.មូលហេតុនៃការលុបចោលកិច្ចសន្យា** ........................................ ៤

**១.២.១.វិការៈក្នុងការបង្ហាញឆន្ទៈ** ........................................ ៥

**១.២.១.១ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ** ........ ៥

ក.ការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ........................ ៥

ខ.ការភាន់ច្រឡំទៅលើចំណុចសំខាន់ដែលនាំឲ្យបង្កើតកិច្ចសន្យា .............. ៦

គ.ការភាន់ច្រឡំដោយភាគីទាំងសងខាង ........................................ ៧

**១.២.២.២.ការឆបោក** ........................................ ៧

ក.ករណីឆបោកដោយភាគីម្ខាងទៀត ........................................ ៨

ខ.ការឆបោកដោយតតិយជន ........................................ ៨

**១.១.២.៣.ព័ត៌មានមិនពិត** ........................................ ៩

**១.១.២.៤.ការរំលោភបំពានលើស្ថានភាព** ........................................ ១០

**១.១.២.៥.ការគម្រាមកំហែង** ........................................ ១១

**១.១.២.៦.ការកេងចំណេញហួសហេតុ** ........................................ ១១

**១.២.២.ការខ្វះសមត្ថភាពរបស់គូភាគី** ........................................ ១២

**១.២.២.១.ការខ្វះសមត្ថភាពខាងឆន្ទៈ** ........................................ ១៣

**១.២.២.២.ការខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព** ........................................ ១៣

ក.អនីតិជន ........................................ ១៣

ខ.ជននៅក្រោមអាណាព្យាបាលទូទៅ ........................................ ១៧

គ.ជននៅក្រោមហិត្ថបត្ថម្ភ..........................................................................២០

**ជំពូកទី២**

**អ្នកមានសិទ្ធិលុបចោល និងការផ្តល់សច្ចានុមតិ**

**២.១.អ្នកដែលមានសិទ្ធិលុបចោល និងការផ្តល់សច្ចានុមតិ**..............................២២
**២.១.១.អ្នកមានសិទ្ធិលុបចោលកិច្ចសន្យាដែលមានវិការៈ**.........................២២
**២.១.២.អ្នកមានសិទ្ធិលុបចោលកិច្ចសន្យាធ្វើឡើងដោយ ជនខ្វះសមត្ថភាព**..........................................................................២៣
**២.១.៣.អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ**..........................................................២៤
**២.២.របៀបនៃការលុបចោលកិច្ចសន្យា និងការផ្តល់សច្ចានុមតិ**.....................២៥
**២.២.១.របៀបនៃការលុបកិច្ចសន្យា**...........................................................២៥
**២.២.២.របៀបផ្តល់សច្ចានុមតិ**...................................................................២៦
**២.៣.អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោលកិច្ចសន្យា**.................................២៨
**២.៤.អានុភាពនៃការលុបចោលកិច្ចសន្យា**.........................................................៣០
**សេចក្តីសន្និដ្ឋាន**............................................................................................៣២
**អនុសាសន៍**....................................................................................................៣៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

បន្ទាប់ពីបានឆ្លងកាត់នូវការសិក្សាលើមុខជំនាញច្បាប់កន្លងមក យើងអាចយល់បានថា ច្បាប់ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បី ការពារសិទ្ធិ សេរីភាព សេចក្តីថ្លៃថ្នូរ សន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយនៅក្នុងប្រទេសនីមួយៗ ឲ្យមានសន្តិភាព ភាពសុខដុមរមនា នៃការរស់នៅក្នុងសង្គមជាតិរៀងៗខ្លួនក៏ដូចជាពិភពលោកទាំងមូលផងដែរ។ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ យើងបានបង្កើតកិច្ចសន្យាជាច្រើន ដែលពេលខ្លះយើងពុំចាប់អារម្មណ៍ឡើយ។ ជាពិសេសការធ្វើជំនួញជួញដូរ គឺជាសកម្មភាពភាពមួយដែលកើតមានឡើងជាហូហែរនៅក្នុងសង្គមសេដ្ឋកិច្ចទីផ្សារសេរី។ ដើម្បីឲ្យការជួញដូរមានភាពរលូន ភាគីនៃការជួញដូរ គួរតែមានសេរីភាព និងសមភាពនៅក្នុងការជួញដូរ។ ហេតុដូច្នេះហើយ ទើបក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានកំណត់គោលការណ៍ស្វ័យភាពបុគ្គលឯកជន ផ្តល់សិទ្ធិឲ្យភាគីនៃកិច្ចសន្យាអាចកំណត់ពីខ្លឹមសារនៃកិច្ចសន្យាសេរីតាមឆន្ទៈរបស់ខ្លួន ដោយមិនត្រូវចង់ដោយឆន្ទៈបុគ្គលដទៃឡើយបើខ្លួនមិនព្រម។ បន្ថែមពីនេះទៀតផងដែរ នៅក្នុងទំនាក់ទំនងកិច្ចសន្យា តែងមានបុគ្គលដែលមានករណីកិច្ច ឬហៅថាកូនបំណុល និងបុគ្គលដែលជាអ្នកទទួលផលប្រយោជន៍ ឬហៅថាម្ចាស់បំណុល ដូច្នេះហើយ ភាគីនៃកិច្ចសន្យាត្រូវប្រើសិទ្ធិ ឬអនុវត្តន៍ករណីកិច្ចដោយគោរពទៅតាមគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់។ យ៉ាងណាមិញ ប្រជាពលរដ្ឋកម្ពុជាយើងមួយចំនួនបានស្វែងយល់ពីច្បាប់ជាមុន មុននឹងបង្កើតកិច្ចសន្យាផ្សេងៗនោះទេ ខណៈដែលមានបញ្ហាកើតឡើង ទើបស្វែងរកអ្នកច្បាប់ឲ្យជួយដោះស្រាយ លើកលែងតែអ្នកវិនិយោគ អ្នកជំនួញ ឬអាជីវករ អ្នករកស៊ីធំៗ ដែលពួកគាត់តែងតែមានទីប្រឹក្សាច្បាប់ម្នាក់ ឬច្រើន ដើម្បីប្រឹក្សាយោបល់ផ្នែកច្បាប់ផ្សេងៗ ជៀសវាងមានបញ្ហាប៉ះពាល់ដល់កិច្ចការជំនួញរបស់ខ្លួន។ កិច្ចសន្យាដែលកើតឡើងជាញឹកញាប់នៅក្នុងជីវិតប្រចាំថ្ងៃ ក៏ដូចជានៅក្នុងសង្គមកម្ពុជាយើងមានដូចជា៖ កិច្ចសន្យាទិញលក់ កិច្ចសន្យាអាណត្តិ កិច្ចសន្យាខ្ចីប្រើ ភតិសន្យា កិច្ចសន្យាការងារ កិច្ចសន្យាម៉ៅ កិច្ចសន្យាខ្ចីបរិភោគ ជាដើម។ ដូចដែលយើងដឹងហើយថា ប្រទេសកម្ពុជាយើង គឺជាប្រទេសនីតិរដ្ឋដូចនេះការធ្វើអ្វីផ្សេងៗត្រូវតែអនុលោមទៅតាមច្បាប់ ហើយច្បាប់អាចការពារ និងផ្តល់អត្ថប្រយោជន៍ដល់យើងបានលុះត្រាតែយើងគោរពទៅតាមបញ្ញត្តិច្បាប់។ ហេតុនេះហើយ ទោះបីជាកិច្ចសន្យាត្រូវបានបង្កើតឡើងក៏ដោយ ប្រសិនបើកិច្ចសន្យានោះ ពុំបានបំពេញនូវលក្ខខណ្ឌដែលកំណត់ដោយច្បាប់ ឬផល់ផលប៉ះពាល់ដល់ភាគីនៃកិច្ចសន្យា និងសង្គម នោះកិច្ចសន្យានឹងប្រឈមនឹងការប្រកាសលុបចោលទៅវិញ ឬត្រូវបានចាត់ទុកជាមោឃៈជាការគួរកត់សម្គាល់មួយគឺ ជាគោលការណ៍ កិច្ចសន្យាមានអានុភាពត្រឹមដំណាក់កាលសំណើ និងស្វីការត្រូវគ្នា តែក៏មានកិច្ចសន្យាខ្លះទាមទារឲ្យបំពេញលក្ខខណ្ឌបន្ថែមទៀតក្រៅពីមានភាពត្រូវគ្នារវាងសំណើ និងស្វីការ។ ជាក់ស្តែង ចំពោះកិច្ចសន្យាដែលមានការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុនឹងមានអានុភាពបាន លុះត្រាតែ

បានធ្វើលិខិតយថាភូតបន្ថែមពីភាពត្រូវគ្នារវាងសំណើ និងស្វីការ។ នៅពេលដែលកិច្ចសន្យាមានអានុភាព បង្កើតឲ្យទំនាក់ទំនងគតិយុត្ត ដោយភាគីនៃកិច្ចសន្យាត្រូវតែអនុវត្តករណីកិច្ចដែលមាននៅក្នុងកិច្ចសន្យានោះ ដោយមិនអាចប្រកែកបាន។ ប៉ុន្តែក្នុងករណីខ្លះភាគីនៃកិច្ចសន្យាអាចបដិសេធការអនុវត្តកិច្ចសន្យានោះបាន ដោយសារតែកិច្ចសន្យានោះមានមោឃភាព ឬជាកិច្ចសន្យាដែលមានមូលហេតុនៃការលុបចោល។ ចំពោះកិច្ចសន្យាដែលមានការលុបចោលគឺ កិច្ចសន្យានោះនៅតែមានអានុភាព ដរាបណាអ្នកដែលមានសិទ្ធិលុបចោលកិច្ចសន្យានោះមិនបានលុបចោលកិច្ចសន្យានោះ ដូច្នេះហើយ តើក្នុងដំណាក់កាលណាដែលអាចឲ្យគេប្រកាសលុបចោលកិច្ចសន្យា? តើនរណាខ្លះមានសិទ្ធិលុបចោលកិច្ចសន្យា? ហើយថាតើការប្រកាសលុបចោលកិច្ចសន្យានាំអោយមានអានុភាពបែបណា?

ភ្ជាប់ទៅនឹងការរៀបរាប់ខាងលើ បើយើងក្រឡេកមើលបទប្បញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ យើងអាចធ្វើការបែងចែកជាពីរគឺ ចំពោះកិច្ចសន្យាដែលមានផលប៉ះពាល់ត្រឹមជាលក្ខណៈបុគ្គល ពោលគឺភាគីនៃកិច្ចសន្យា នោះកិច្ចសន្យាអាចត្រូវបានលុបចោល។ លើសពីនេះ ប្រសិនបើកិច្ចសន្យាមានផលប៉ះពាល់ជាលក្ខណៈសាធារណៈដូចជា៖ ទំនៀមទម្លាប់សណ្តាប់ធ្នាប់ល្អរបស់សង្គម ឬផ្ទុយច្បាប់ជាដើម កិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈ។ ដោយសារតែប្រធានបទនេះសិក្សាតែ ការលុបចោលកិច្ចសន្យា ខ្ញុំបាទសូមមិនធ្វើការបកស្រាយបន្ថែមពីមោឃភាពនៃកិច្ចសន្យាទៀតទេ ដើម្បីកុំឲ្យមានការឃ្លាតឆ្ងាយពីប្រធានបទ។

ដូចនេះ ការស្វែងយល់ក្នុងការសិក្សាអំពីការលុបចោលកិច្ចសន្យា ពិតជាមានសារៈសំខាន់ណាស់ នៅក្នុងសារណានេះ ខ្ញុំនឹងធ្វើការបែងចែកប្រធានបទជាពីរ គឺ៖

លក្ខខណ្ឌនៃការលុបចោលកិច្ចសន្យា (ជំពូកទី១)

និងអ្នកមានសិទ្ធិលុបចោល និងការផ្តល់សច្ចានុមតិ (ជំពូកទី២)។

# ជំពូកទី១

# លក្ខខណ្ឌនៃការលុបចោលកិច្ចសន្យា

## ១.១.អត្ថន័យនៃការលុបចោលកិច្ចសន្យា

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច។[1] ក្នុងន័យនេះ កិច្ចសន្យាគឺជាការត្រូវគ្នានៃឆន្ទៈ ដែលចង់បង្កើតកែប្រែ ឬរំលត់ កាតព្វកិច្ច។ កិច្ចសន្យា ដែលបង្កើតឡើងត្រូវតែបម្រើឲ្យផលប្រយោជន៍បុគ្គល និងផលប្រយោជន៍សង្គម ហើយភាគីនៃកិច្ចសន្យាត្រូវអនុវត្តន៍កិច្ចសន្យាដោយស្មោះត្រង់ និងសីលធម៌សង្គម។[2]

ជាគោលការណ៍ កាលណាមានការព្រមព្រៀងរបស់ភាគីនៃកិច្ចសន្យាដោយសារសំណើ និងស្ទីការត្រូវគ្នា កិច្ចសន្យានឹងបង្កើតអានុភាព[3] លើកលែងតែការបង្កើតកិច្ចសន្យាមួយចំនួនដូចជា ការប្រគល់វត្ថុ ឬ ការរៀបចំលិខិត តម្រូវឲ្យមានលក្ខខណ្ឌដែលចាំបាច់បន្ថែមពីការព្រមព្រៀងគ្នា ទើបកិច្ចសន្យាមានអានុភាព។[4] នេះគឺជាលក្ខខណ្ឌដែលច្បាប់តម្រូវឲ្យបំពេញបន្ថែម ចំពោះកិច្ចសន្យាពិសេសជាក់លាក់ណាមួយ ព្រោះត្រឹមតែមានការព្រមព្រៀង គឺមិនគ្រប់គ្រាន់នោះទេក្នុងការបង្កើតអានុភាពកិច្ចសន្យា។

ម្យ៉ាងទៀតចំពោះ កិច្ចសន្យាដែលភាគីម្ខាងទទួលករណីកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនឹងមានអនុភាព លុះត្រាតែបានធ្វើលិខិតយថាភូត។[5] ការកំណត់អំពីលក្ខខណ្ឌបន្ថែមទាំងនេះ គឺដើម្បីធានាបានការការពារអនុប្បទាយី អនុប្បទានិក ជាពិសេសគឺជួយសម្របសម្រួលក្នុងការកាត់បន្ថយវិវាទ ការដោះស្រាយជម្លោះ ឬ ការពារជម្លោះមិនឲ្យកើតមានឡើងនៅពេលដែលមានវិវាទកិច្ចសន្យានៃការអនុប្បទានកម្មសិទ្ធិលើអចលនវត្ថុ។

សំណើរ គឺជាការស្នើសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។[6] ចំណែកស្ទីការវិញ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនេះ។[7]

---

[1] មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, (ពីពេលនេះតទៅហៅថាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)

[2] ច្បាប់កិច្ចសន្យា, ជ្រា ឈុនឡេង, ទំព័រ៣, ឆ្នាំ២០១៦

[3] មាត្រា ៣៣៦ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[4] សេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមរដ្ឋប្បវេណីភាគ២, កំណត់មាត្រា៣៣៦

[5] មាត្រា ៣៣៦ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[6] មាត្រា ៣៣៧ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[7] មាត្រា ៣៣៧ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ការលុបចោល គឺជាបច្ចេកទេសមួយដើម្បីធ្វើការបដិសេធអនុភាពនៃកិច្ចសន្យា។[8] ម្យ៉ាងទៀតសំដៅលើការបដិសេធសុពលភាពរបស់សកម្មភាពណាមួយដែលវាមានសុពលភាពតាំងពីដំបូង ដោយមានអានុភាពប្រតិសកម្ម។

គោលគំនិតសំខាន់ក្នុងការលុបចោលកិច្ចសន្យានេះ គឺអាចនិងមានស្ថានភាពពីយ៉ាង ដូចខាងក្រោមគឺ៖

- បានរួចផុតពីកាតព្វកិច្ចដែលបានកើតឡើងដោយសារកិច្ចសន្យា ពោលគឺកាតព្វកិច្ចទាំងអស់ដែលភាគីមាននៅក្នុងកិច្ចសន្យាដែលធ្វើឡើងត្រូវបានបញ្ចប់និងមិនមាននូវកាតព្វកិច្ចក្នុងការបំពេញវាទេ។
- អាចយកមកវិញនូវវត្ថុ ឬ ប្រាក់ដែលបានប្រគល់ជាតាវកាលិក តាមរយៈកាតព្វកិច្ចដែលបានកើតឡើងដោយសារកិច្ចសន្យានោះ។ ភាគីនៃកិច្ចសន្យាអាចទទួលបាននូវកម្មវត្ថុនៃកិច្ចសន្យានេះបានវិញតាមការលុបចោលនូវកិច្ចសន្យានេះ តាវកាលិកនេះអាចជាតាវកាលិកនាពេលបច្ចុប្បន្ន និងអាចជាតាវកាលិកនាពេលអនាគត។

## ១.២.មូលហេតុនៃការលុបកិច្ចសន្យា

ក្រមរដ្ឋប្បវេណី គឺជាក្រមមួយដែលចែងអំពីទំនាក់ទំនងរវាងបុគ្គលនិងបុគ្គល ទ្រព្យសម្បត្តិ និងគ្រួសារហើយក្រមរដ្ឋប្បវេណីនេះផងដែរក៏បានបញ្ញត្តិនូវសកម្មភាពរបស់បុគ្គលនៅក្នុងសង្គម ដែលធ្វើនូវសកម្មភាព ដោះដូរនូវទំនិញនឹងសកម្មភាពជួញដូរណាមួយ នៅក្នុងជីវភាពប្រចាំថ្ងៃរបស់មនុស្សក្នុងសង្គម។ តួយ៉ាងយើងឃើញថា នាពេលបច្ចុប្បន្ននេះសកម្មភាពដោះដូរទាំងនេះដែលប្រជាជនបានធ្វើ គឺមានសកម្មភាពមួយចំនួនត្រូវបានគូភាគីនៃកិច្ចសន្យាបានធ្វើការបដិសេធចោល ឬ អាចនិងត្រូវបានគូភាគីបានលុបចោលផងក៏មានដែរ។ ដោយសារតែសកម្មភាពដែលធ្វើឡើងនេះជាសកម្មភាពដែលត្រូវបានច្បាប់ការពារ និងច្បាប់បានធ្វើការហាមឃាត់ចំពោះសកម្មភាពទាំងនោះ។ មូលហេតុដែលនាំឲ្យមាននូវការលុបចោលនូវកិច្ចសន្យា ដែលភាគីបានធ្វើឡើងនោះដោយសារតែភាគីនៃកិច្ចសន្យា បានបង្កើតកិច្ចសន្យាដែលមិនស្របទៅនឹងលក្ខខណ្ឌគ្រឹះនៃកិច្ចសន្យាដែលបានកំណត់ដោយច្បាប់។

ផ្ទុយទៅវិញនៅក្នុងកិច្ចសន្យាគូភាគីម្ខាងនៃកិច្ចសន្យាដែលបានធ្វើកិច្ចសន្យា ជាមួយនឹងភាគីម្ខាងទៀតដោយមានជួបប្រទះនូវការប្រើប្រាស់នូវឧបាយកល ការបោកប្រាស់ ការក្លែងបន្លំ ការភាន់ច្រឡំដោយខ្លួនឯង ឬភាគីម្ខាងទៀតធ្វើឲ្យច្រឡំនូវចំណុចណាមួយនៃកិច្ចសន្យា ការគម្រាមកំហែង ការប្រើប្រាស់ឋានៈរបស់ខ្លួន

[8] មេរៀនភាគ ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៨, ២០១៦។

ដើម្បីគាបសង្កត់ភាគីម្ខាងទៀត ការឆ្លៀតឱកាសយកផលប្រយោជន៍ផ្សេងៗ និងការធ្វើកិច្ចសន្យាជាមួយអសមត្ថជន ភាគីម្ខាងដែលបានជួបប្រទះបញ្ហាទាំងនេះអាចធ្វើការលុបចោលកិច្ចសន្យានោះបាន ។

### ២.១.១.វិការៈនៃការបង្ហាញឆន្ទៈ

ដើម្បីជាមូលដ្ឋានក្នុងការស្វែងយល់នូវចំណុចនីមួយៗ នៃការបង្ហាញឆន្ទៈដោយមានវិការៈ យើងគប្បីយល់អត្ថន័យនៃពាក្យ "**វិការៈ**" និង "**ការបង្ហាញឆន្ទៈ**" ជាមុនសិន។ យោងតាមសន្ទានុក្រមនៃក្រមរដ្ឋប្បវេណី ចំណុច១៣៥ ពាក្យថា "វិការៈ" មានន័យថា ការប្រែប្រួលចាកពីភាពប្រក្រតី។ ចំណែកឯពាក្យ "**ការបង្ហាញឆន្ទៈ**" មានចង្អុលបង្ហាញនៅក្នុងមាត្រា៣១០ កថាខណ្ឌ១ ដែលសំដៅលើការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្ត។ ដូចនេះ **វិការៈនៃការបង្ហាញឆន្ទៈ** មានន័យថា ការប្រែប្រួលចាកពីភាពប្រក្រតីនៃការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្ត។ ជាទូទៅ ការបង្ហាញឆន្ទៈ មានលក្ខណៈពិតប្រាកដដោយសេរី និងស្ម័គ្រចិត្ត ពោល គឺពុំត្រូវមានហេតុណាមួយដែលធ្វើឲ្យឆន្ទៈបង្ហាញដែលនោះ មានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណី ចាប់ពីមាត្រា៣៤៦ ដល់មាត្រា៣៥១ រួមមាន៖ ការបង្ហាញឆន្ទៈដោយមានការភាន់ច្រឡំ ការបង្ហាញឆន្ទៈដោយមានការឆបោក ការបង្ហាញឆន្ទៈព្រោះទទួលបានព័ត៌មានមិនពិត ការបង្ហាញឆន្ទៈដោយស្ថិតក្នុងការរំលោភលើស្ថានភាព ការបង្ហាញឆន្ទៈដោយមានការគម្រាមកំហែង និងការបង្ហាញឆន្ទៈដែលភាគីម្ខាងទៀតបានកេងចំណេញយ៉ាងហួសហេតុ។

យើងសូមធ្វើការបង្ហាញពីចំណុចនីមួយៗដូចខាងក្រោម៖

#### ១.២.១.១.ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ

ការភាន់ច្រឡំ មានន័យថានៅក្នុងករណីដែលអ្នកបង្ហាញឆន្ទៈបានធ្វើការបង្ហាញឆន្ទៈដែលមានលក្ខណៈខុសគ្នាទៅនឹងឆន្ទៈពិតរបស់ខ្លួន ហើយភាគីនៃកិច្ចសន្យានោះក៏មិនបានដឹងអំពីភាពខុសគ្នានេះ នៅពេលដែលគេធ្វើការបង្ហាញឆន្ទៈឡើយ។ ឧទាហរណ៍ ដូចជាក្នុងការរស់នៅប្រចាំថ្ងៃមានអាជីវករប្រកបរបរលក់ដូរចិញ្ចឹមជីវិត នៅពេលដែលអ្នកលក់ធ្វើការគិតលុយដោយខ្វះលេខសូន្យមួយខ្ទង់ យើងឃើញថា អ្នកលក់នឹងត្រូវប្រឈមមុខនឹងការខាតបង់ខ្ពស់។ ដូច្នេះហើយ ដើម្បីការពារហានិភ័យដែលអាចកើតឡើងនៅពេលដែលមានការភាន់ច្រឡំ ច្បាប់អនុញ្ញាតឲ្យភាគីដែលបង្ហាញឆន្ទៈដោយមានការភាន់ច្រឡំ អាចលុបចោលកិច្ចសន្យានោះបាន។ យោងតាមមាត្រា ៣៤៦ នៃក្រមរដ្ឋប្បវេណី បានបែងចែកស្ថានភាពនៃការភាន់ច្រឡំជា ០៣(បី) ប្រភេទដូចខាងក្រោមគឺ៖

ក.ការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា

កិច្ចសន្យាដែលបានបង្កើតឡើងហើយអាចលុបចោលបាន ប្រសិនបើកិច្ចសន្យានោះ ត្រូវបានធ្វើឡើងដោយភាគីម្ខាងមានការភាន់ច្រឡំទៅលើចំណុចសំខាន់ៗនៃកិច្ចសន្យា និងខណៈដែលភាគីម្ខាងទៀតបានស្ថិតក្នុងស្ថានភាពដែលអាចដឹងបានអំពីការភាន់ច្រឡំនេះ ។

លក្ខខណ្ឌ៖

- ➢ ការភាន់ច្រឡំអំពីចំណុចសំខាន់នៃកិច្ចសន្យា (អ្នកបង្ហាញឆន្ទៈ)
- ➢ ស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំ (ភាគីម្ខាងទៀត)

ឧទាហរណ៍៖ A ជាអ្នកលក់ទូរស្សន៍ ហើយនៅក្នុងហាងមានទូរស្សន៍ម៉ាក PANASONIC ចំនួន ០២ គ្រឿង ដោយមួយគ្រឿងជាទូរស្សន៍ថ្មី និងមួយគ្រឿងទៀតជាទូរស្សន៍មួយទឹកមកពីស្រុកក្រៅ។ ហើយ B ចង់ទិញទូរស្សន៍ម៉ាក PANASONIC ថ្មី ហើយក៏បានយល់ព្រមទិញក្នុងតម្លៃ៦០០ដុល្លារអាមេរិក តែដោយទូរស្សន៍ទាំងពីរមានសភាពប្រហាក់ប្រហែលគ្នា B ក៏បានអង្គុលឲ្យ A វេចខ្ចប់ច្រឡំទូរស្សន៍មួយទឹក។ នៅពេលដែល B យល់ព្រមទិញក្នុងតម្លៃ ៦០០ដុល្លារអាមេរិក នោះ A អាចនឹងដឹងថា B ចង់ទិញទូរស្សន៍ថ្មី ដោយពិនិត្យមើលទៅលើតម្លៃដែលបានចចារគ្នា។ ដូចនេះ B អាចលុបចោលកិច្ចសន្យាបាន ដោយសារការភាន់ច្រឡំ។

ប៉ុន្តែមិនមែនគ្រប់ករណីភាន់ច្រឡំសុទ្ធតែអាចលុបចោលបាននោះទេដើម្បីការពារផលប្រយោជន៍ភាគីម្ខាងទៀត និងការពារដល់សុវត្ថិភាពក្នុងការធ្វើជំនួញ ទាល់តែភាគីម្ខាងទៀតអាចដឹងអំពីការភាន់ច្រឡំ ទើបភាគីដែលភាន់ច្រឡំអាចលុបចោលកិច្ចសន្យានោះបាន។

ខ.ការភាន់ច្រឡំទៅលើចំណុចសំខាន់ដែលនាំឲ្យបង្កើតកិច្ចសន្យា

កិច្ចសន្យាដែលបានបង្កើតឡើងហើយអាចលុបចោលបាន ប្រសិនបើកិច្ចសន្យានោះ មានការភាន់ច្រឡំទៅលើចំណុចនៃកិច្ចសន្យា ដែលភាគីយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ខណៈដែលភាគីម្ខាងទៀតបានស្ថិតក្នុងស្ថានភាពដែលអាចដឹងបានអំពីការភាន់ច្រឡំនេះ និងការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈ ។

លក្ខខណ្ឌ៖

- ➢ ចំពោះភាគីម្ខាងនៃកិច្ចសន្យាមានការភាន់ច្រឡំអំពី៖
  - ចំណុចដែលខ្លួនបានយល់ឃើញថាសំខាន់ ឬ
  - ចំណុចដែលខ្លួនបានយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា
- ➢ ភាគីម្ខាងទៀតស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និងការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈ។

ឧទាហរណ៍៖ នៅក្នុងប្រទេសកម្ពុជា អ្នកធ្វើស្រែចំការភាគច្រើនគិតអំពីហ៊ុងស៊ុយរបស់ប្រើប្រាស់របស់គេណាស់។ មានអ្នកធ្វើស្រែកចំការ A ដ៏ល្បីល្បាញម្នាក់ដែលមានមុខស្មើតែគ្រប់ប្រព័ន្ធផ្សព្វផ្សាយ គាត់ទៅណាមកណាប្រើប្រាស់តែម៉ូតូពណ៌ខ្មៅ ព្រោះគាត់គិតថាពណ៌ខ្មៅ ជាពណ៌ដែនាំហ៊ុងស៊ុយឲ្យគាត់។ A បានទៅទិញម៉ូតូនៅក្នុងហាងលក់ម៉ូតូរបស់ B ដោយសារតែពេលនោះស្ថិតនៅក្នុងស្ថានភាពដែលមេឃស្រទុំ ពុំសូវមានពន្លឺគ្រប់គ្រាន់ នាំឲ្យគាត់មើលឃើញពណ៌ខៀវស្រគាំ ថាជាពណ៌ខ្មៅ។ លុះដល់ពេលប្រគល់ម៉ូតូទើបគាត់ដឹងពីបញ្ហានេះ។ ដូចនេះស្ថិតនៅក្នុងស្ថានភាពនេះ B អាចដឹងអំពីរឿងនេះ ដែលនាំឲ្យ A អាចលុបចោលនូវកិច្ចសន្យានេះបាន។

គ.ការភាន់ច្រឡំដោយភាគីទាំងសងខាង

នៅក្នុងករណីមានការភាន់ច្រឡំដោយភាគីទាំងសងខាង អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបានទោះបីជាភាគីម្ខាងទៀត មិនបានដឹងអំពីការភាន់ច្រឡំនេះក៏ដោយ។ នៅក្នុងករណីនេះគូភាគីទាំងសងខាងមានការភាន់ច្រឡំដូច្នេះ ភាពចាំបាច់នៅក្នុងការការពារភាគីម្ខាងទៀត គឺមានកម្រិតទាប ដែលខុសពីករណីដែលមានតែភាគីម្ខាងមានការភាន់ច្រឡំ។ ដូច្នេះវាមិនមានភាពចាំបាច់ក្នុងការពិចារណាទៅលើលទ្ធភាពក្នុងការដឹងរបស់ភាគីម្ខាងទៀតទេ ។

លក្ខខណ្ឌ៖

- ភាគីទាំងសងខាងមានការភាន់ច្រឡំទៅលើចំណុចណាមួយនៃកិច្ចសន្យាដូចគ្នា
- ចំណុចដែលមានការភាន់ច្រឡំ គឺជាចំណុចសំខាន់នៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា។

ភាពខុសគ្នានៃការលុបចោលកិច្ចសន្យាក្នុងករណីមានការភាន់ច្រឡំដោយភាគីទាំងសងខាងនេះខុសពីករណីភាន់ច្រឡំទាំងពីរខាងលើត្រង់ថា ការភាន់ច្រឡំដោយភាគីទាំងសងខាង ភាគីណាក៏អាចលុបចោលកិច្ចសន្យាបានដែរ ទោះបីភាគីម្ខាងទៀតមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំនេះក៏ដោយ។

ឧទារហណ៍៖ A និង B បានធ្វើកិច្ចសន្យាទិញលក់រថយន្តមួយ ដោយយល់ច្រឡំដូចគ្នា ជារថយន្តបុរាណ។ ករណីនេះ A អាចលុបចោលកិច្ចសន្យានោះបាន ទោះបីជា B ស្ថិតនៅក្នុងស្ថានភាពមិនអាចដឹងអំពីការភាន់ច្រឡំក៏ដោយ។

**១.២.២.២.ការឆបោក**

ការបង្ហាញឆន្ទៈដោយការឆបោក មានន័យថាបុគ្គលណាម្នាក់ ឬតតិយជនបានធ្វើឲ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំដោយសារមធ្យោបាយឆបោក ហើយអ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈរបស់ខ្លួន ដោយ

ខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន និងមិនបានដឹងពីភាពខុសគ្នានេះនៅពេលដែលគាត់ធ្វើការបង្ហាញឆន្ទៈ។[9] ការឆបោក ក៏ជាកត្តាដែលនាំឲ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំផងដែរ។ ប៉ុន្តែការភាន់ច្រលំនៅទីនេះ វាកើតឡើងដោយការបោកបញ្ឆោត បន្លំ បោកប្រាស់ ប្រើល្បិចកលជាដើមពីសំណាក់ភាគីម្ខាងទៀត ឬ តតិយជន។ វាមានភាពចាំបាច់យ៉ាងខ្លាំងក្នុងការការពារជនរងគ្រោះដែលបានបង្ហាញឆន្ទៈដោយសារការឆបោកនោះ។ ក៏ប៉ុន្តែមិនមែនរាល់ការឆបោកទាំងអស់សុទ្ធតែជាមូលដ្ឋាននៃការលុបចោលកិច្ចសន្យានោះទេ។ មានការឆបោកមួយចំនួនដែលមានលក្ខណៈតិចតួច មិនប៉ះពាល់ដល់សារធាតុសំខាន់នៃកិច្ចសន្យា ត្រូវបានសង្គមទទួលស្គាល់ថា ទោះបីជាមានការឆបោកក៏ដោយ ក៏មិនអាចលុបចោលកិច្ចសន្យានោះបានដែរ។

ឧទាហរណ៍ A បានទៅរកទិញកាបូបលុយនៅក្នុងហាងកាបូបរបស់B។ B បានលក់កាបូបលុយម៉ាកC ទៅឲ្យ A ដោយកុហសថា ជាកាបូបលុយដែលកំពុងពេញនិយមនាពេលបច្ចុប្បន្ន និងលក់ដាច់ជាងគេនៅក្នុងហាង។ ដូច្នេះក្នុងករណីនេះជាការឆបោកដែលសង្គមទទួលស្គាល់។

ការឆបោក ពេលខ្លះធ្វើឡើង ក.ករណីឆបោកបោកដោយភាគីម្ខាងទៀត ពេលខ្លះធ្វើឡើង ខ.ការឆបោកដោយតតិយជន។

ក.ករណីឆបោកបោកដោយភាគីម្ខាងទៀត

នៅពេលដែលកិច្ចសន្យាមួយត្រូវបានបង្កើតឡើង ដោយមានការឆបោកពីសំណាក់ភាគីម្ខាងទៀតក្នុងកិច្ចសន្យានោះ យើងមិនចាំបាច់ពិចារណាច្រើននោះទេ ព្រោះច្បាប់មិនការពារជនដែលមានគំនិតទុច្ចរិតដើរបោកប្រាស់អ្នកដទៃឡើយ។ ហេតុដូចនេះ បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[10]

លក្ខណៈ

- ភាគីម្ខាងបានផ្តល់ពត៌មានមិនពិតដោយចេតនា (ឆបោក)
- ភាគីម្ខាងទៀតបានបង្ហាញឆន្ទៈខុសពីឆន្ទៈពិត ដោយសារការឆបោកនោះ។

ឧទាហរណ៍ A បានទៅរកទិញចានដែលផលិតនៅប្រទេសសហរដ្ឋអាមេរិក នៅហាងរបស់B។ ពេលនោះB បានយកចានដែលផលិតនៅប្រទេសបារាំងលក់ឲ្យទៅ A ដោយកុហសថាចាននិងផលិតផលរបស់ប្រទេសសហរដ្ឋអាមេរិក។ ក្នុងករណីនេះ A អាចលុបចោលកិច្ចសន្យាវិញបាន។

ខ.ការឆបោកដោយតតិយជន

[9]សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ១ រៀបចំដោយក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ទំព័រ១២៧ ឆ្នាំ២០១៣

[10]មាត្រា៣៤៧ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ការឆបោក ពេលខ្លះធ្វើដោយតតិយជន មិនមែនធ្វើឡើងដោយភាគីនោះទេ។ នៅពេលដែលកិច្ចសន្យាមួយត្រូវបានបង្កើតឡើងដោយមានការឆបោកពីតតិយជន ហើយភាគីម្ខាងទៀតពុំបានដឹងអំពីការឆបោកនោះឡើយ ដូចនេះ ប្រសិនបើយើងអនុញ្ញាតឲ្យភាគីដែលបង្ហាញឆន្ទៈដោយមានការឆបោកនោះ អាចលុបចោលកិច្ចសន្យានោះបាន វាហាក់បីដូចជាអយុត្តិធម៌ណាស់សម្រាប់ភាគីម្ខាងទៀត។ ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជនអ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យា ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈលុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹង ឬ អាចដឹងអំពីការឆបោកនោះ។[11]

លក្ខខណ្ឌ៖

- ភាគីម្ខាងនៃកិច្ចសន្យាត្រូវបានឆបោកដោយតតិយជន
- ភាគីម្ខាងទៀតបានដឹង ឬ អាចដឹងអំពីការឆបោកនោះ

ឧទាហរណ៍ A មានចានធម្មតាមួយ។ B បានប្រាប់ទៅ C ថា ចាននោះជាចានដ៏កម្រ ដែលជាវត្ថុបុរាណក្នុងសម័យកាលគ.ស។ ពេលនោះ C បានទិញចាននោះក្នុងតម្លៃយ៉ាងថ្លៃ។ ក្នុងករណីនេះ បើយើងក្រឡេកមើលទៅ A គឺគេបានដឹងថា ចានរបស់ខ្លួនគ្រាន់តែជាចានធម្មតាមួយតែប៉ុណ្ណោះ ហើយបើ C បានដឹងថាចាននោះជាចានធម្មតានោះ ក៏ C មិនហ៊ានទិញក្នុងតម្លៃថ្លៃបែបនេះឡើយ ដូចនេះ C គប្បីត្រូវបានការការពារ ដោយ C អាចលុបចោលកិច្ចសន្យានោះវិញបាន។

**១.១.២.៣.ព័ត៌មានមិនពិត**

ដូចដែលបានធ្វើការបកស្រាយខាងលើ ប្រសិនបើភាគីម្ខាងបានផ្តល់ពត៌មានមិនពិតដោយចេតនានោះសកម្មភាពនោះត្រូវបានគេចាត់ទុកថា ជាការឆបោក។ ផ្ទុយទៅវិញ ប្រសិនបើភាគីម្ខាងបានផ្តល់ពត៌មានមិនពិតដោយពុំមានចេតនាទេនោះ វាត្រូវបានគេចាត់ទុកថាជាការផ្តល់ពត៌មានមិនពិត។ ពត៌មានមិនពិត សំដៅលើហេតុដែលត្រូវបានលើកឡើងជាមូលដ្ឋានក្នុងការបង្កើតកិច្ចសន្យា គឺខុសពីការពិត។ នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបកិច្ចសន្យាបាន។[12]

លក្ខខណ្ឌ៖

[11]មាត្រា៣៨៧ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[12]មាត្រា៣៨៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- ហេតុតែភាគីម្ខាងបានលើកឡើងសម្រាប់ជាមូលដ្ឋានក្នុងការបង្កើតកិច្ចសន្យា គឺខុសពីការពិតទាំងមិនបានដឹងថា វាខុសពីការពិត
- ភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយផ្អែកលើព័ត៌មានមិនពិតនោះ

ឧទាហរណ៍៖ A បានប្រកាសលក់កំសៀវបុរាណមួយ ប៉ុន្តែធាតុពិតគ្រាន់តែជាកំសៀវធម្មតាដែលមានស្ថានភាពរៀងចាស់បន្តិច។ B ជឿជាក់ថា វាជាវត្ថុបុរាណពិតមែន ហើយB ក៏បានទិញកំសៀវនោះ។ ជាការពិតណាស់ ប្រសិនបើ A បានដឹងថា វាគ្រាន់តែជាកំសៀវធម្មតាមួយនោះ វាគឺជាករណីឆបោក ប៉ុន្តែផ្ទុយទៅវិញប្រសិនបើ A មិនបានដឹងទេនោះ ហើយ A ជឿជាក់ថា វាជាវត្ថុបុរាណ នោះវាទើបជាករណីផ្តល់ព័ត៌មានមិនពិត។ ករណីនេះ B អាចធ្វើការលុបចោលកិច្ចសន្យានោះបាន ព្រោះបើ B ដឹងថា កំសៀវនោះជាកំសៀវធម្មតា ក៏ B មិនទិញដែរ។

### **១.១.២.៤.ការរំលោភលើស្ថានភាព**

នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើដោយមិនត្រឹមត្រូវនូវឋានៈរបស់ខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀត ដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[13] ក៏ប៉ុន្តែមិនមែនឲ្យតែភាគីម្ខាងដែលមានឋានៈខ្ពស់ជាង ភាគីម្ខាងទៀតមានឋានៈទាបជាងនោះ អាចលុបចោលកិច្ចសន្យានោះបានទេ លុះត្រាតែការប្រើប្រាស់ឋានៈនោះដោយមិនត្រឹមត្រូវ ហើយអ្នកប្រើឋានៈនោះក៏ដឹង ឬអាចដឹងថា នឹងធ្វើឲ្យប៉ះពាល់ការសម្រេចចិត្តរបស់ភាគីម្ខាងទៀតក្នុងការបង្កើតកិច្ចសន្យា ទន្ទឹងនឹងការសម្រេចចិត្តនេះ ភាគីម្ខាងទៀតនោះក៏មិនអាចប្រឆាំងតបវិញបានដែរ ការលុបចោលកិច្ចសន្យា ដោយហេតុថា មានការរំលោភលើស្ថានភាពនេះ ត្រូវបានបង្កើតឡើងដើម្បីការពារដល់អ្នកទន់ខ្សោយផ្នែកសេដ្ឋកិច្ច ឬ សង្គម។

លក្ខខណ្ឌ៖

- ការប្រើដោយមិនត្រឹមត្រូវនូវឋានៈ (សេដ្ឋកិច្ច ឬ សង្គម) ឬ ស្ថានភាព ដោយភាគីម្ខាង
- ខណៈដែលភាគីម្ខាងទៀតមានឋានៈទាបជាង ឬ មិនអាចប្រឆាំងតប។

ឧទាហរណ៍៖ A ជាប្រធានក្រុមហ៊ុនលក់រថយន្ត បានសុំឲ្យ B ដែលជាបុគ្គលិកនៅក្នុងក្រុមហ៊ុនរបស់ខ្លួនទិញរថយន្តរបស់ខ្លួនដែលបានប្រើប្រាស់អស់រយៈពេលជាង៤ឆ្នាំទៅហើយ ក្នុងតម្លៃ២០.០០០ដុល្លាអាមេរិក តែ

[13]មាត្រា៣៤៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ជាក់ស្តែងរថយន្តនេះថ្មីមានតម្លៃប្រហាក់ប្រហែលនឹងគ្នានេះដែរ។ ដោយសារតែ B ដែលជាបុគ្គលិកមិនហ៊ានប្រកែក ខ្លាចបើប្រកែកB ជាប្រធានក្រុមហ៊ុននឹងបញ្ឈប់ការងារ ទើបAសម្រេចចិត្តទិញរថយន្តរបស់ B ទាំងបង្ខំ។

**១.១.២.៥.ការគម្រាមកំហែង**

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យានោះបាន ដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ។[14] ការគម្រាមកំហែង អាចធ្វើឡើងតាមរូបភាពជាពាក្យសម្តី ឬ កាយវិការ ជាអាទ៍។ យោងទៅតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន គឺបុគ្គលម្នាក់ៗអាចបង្ហាញឆន្ទៈដោយសេរី ពិតប្រាកដ និងស្ម័គ្រចិត្តក្នុងការបង្កើតកិច្ចសន្យា។ ដូចនេះ បើការបង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យានោះមានការបង្ខំតបង្ខំ គម្រាបកំហែង នោះមិនគួរឲ្យកិច្ចសន្យានោះមានសុពលភាពឡើយ ព្រោះវានឹងធ្វើឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ភាគីម្ខាងដែលជាជនរងគ្រោះ។ ដោយសារតែការប៉ះពាល់ដែលកើតចេញពីការគម្រាមកំហែងមានលក្ខណៈធ្ងន់ធ្ងរ ទើបក្រមរដ្ឋប្បវេណីបានការពារជនរងគ្រោះនៃការគម្រាមកំហែងយ៉ាងខ្លាំង ដោយហេតុថា ទោះជាភាគីម្ខាងទៀតគ្មានលទ្ធភាពដឹងអំពីការគម្រាមកំហែងនេះក៏ដោយ ក៏ភាគីម្ខាងដែលជាជនរងគ្រោះអាចលុបចោលកិច្ចសន្យានោះវិញបានដែរ។

លក្ខខណ្ឌ៖

- ភាគីម្ខាង ឬ តតិយជន ប្រាប់ភាគីម្ខាងទៀតអំពីគំនិតព្យាបាទ
- ធ្វើឲ្យភាគីម្ខាងទៀតភ័យខ្លាច
- ភាគីម្ខាងទៀតបានបង្ហាញឆន្ទៈរបស់ខ្លួនដោយសារភាពភ័យខ្លាចនោះ។

ឧទាហរណ៍៖ A បានយល់ព្រមទិញផ្ទះមួយកន្លែងពី B ដោយសារតែ B និយាយថា បើ A មិនទិញផ្ទះនោះទេ B នឹងមិនឲ្យក្រុមគ្រួសារ A រស់នៅបានសុខនោះទេ។ ក្នុងករណីនេះ គឺបានបង្ហាញយ៉ាងច្បាស់អំពីភាពដែលគួរឲ្យអាណិតរបស់ B និងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដែលបានកើតឡើងចំពោះ B។ ដូចនេះ B អាចធ្វើការលុបចោលកិច្ចសន្យានេះបាន ដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ។

**១.១.២.៦.អំពើកេងចំណេញហួសហេតុ**

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះបទពិសោធន៍ ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតអាចលុបចោលកិច្ចសន្យានោះបានដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ។[15] ជាគោលគំនិតក្នុងការបង្កើតកិច្ចសន្យា អ្នកច្បាប់ និងសាធារណៈជនទូទៅតែងតែពិចារណាអំពីភាព

[14]មាត្រា៣៥០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[15]មាត្រា៣៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ស្មើគ្នារវាងគូភាគីនៃកិច្ចសន្យា។ ភាពស្មើគ្នាទាំងនោះមានដូចជា ស្ថានភាព ការបង្ហាញឆន្ទៈ ជាពិសេសផលចំណេញនៃកិច្ចសន្យា។ ការកេងចំណេញហួសហេតុមានលក្ខណៈពិសេសខុសពីការគម្រាមកំហែង និងការរំលោភលើស្ថានភាពដែលពិចារណាអំពីអត្តនោម័តរបស់អ្នកបង្ហាញឆន្ទៈ។ ដោយឡែកការកេងចំណេញហួសហេតុ មិនពិចារណាអំពីអត្តនោម័តរបស់អ្នកបង្ហាញឆន្ទៈឡើយ គឺពិចារណាតែអំពីផលចំណេញដែលភាគីទទួលបានពីកិច្ចសន្យាតែប៉ុណ្ណោះ។ វាជារឿងធម្មតាទេដែលភាគីគ្រប់រូបតែងតែស្វែងរកផលចំណេញរឿងខ្លួនពីកិច្ចសន្យា ប៉ុន្តែប្រសិនបើការចំណេញនោះវាហួសហេតុពេក ក៏មិនគួរគប្បីទទួលស្គាល់កិច្ចសន្យានោះឲ្យមានសុពលភាពដែរ។

លក្ខខណ្ឌ៖

- ភាគីម្ខាងនៃកិច្ចសន្យាបានឆ្លៀតឱកាសដែលភាគីម្ខាងទៀតមានការលំបាកខ្លាំង ឬ មិនដឹង ឬ ខ្វះបទពិសោធន៍ ដើម្បីបង្កើតកិច្ចសន្យា
- ភាគីដែលបានឆ្លៀតឱកាសនោះបានទទួលផលប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់បន្ទាប់ពីកិច្ចសន្យានោះ

មិនមានអ្វីច្បាស់លាស់ដើម្បីកំណត់ពាក្យថា ចំណេញយ៉ាងសន្ធឹកសន្ធាប់ នោះទេ គឺវាប្រែប្រួលតាមករណីជាក់ស្តែង។

ឧទាហរណ៍៖ A មានដីមួយកន្លែកដែលមានតម្លៃ ៥០,០០០ដុល្លារអាមេរិក ដែលត្រូវការលក់ជាបន្ទាន់ដើម្បីយកលុយទៅព្យាបាលម្តាយដែលកំពុងសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ។ ហើយ B ឆ្លៀតក្នុងឱកាសនេះក៏បានយល់ព្រមទិញដីនោះក្នុងតម្លៃត្រឹមតែ ១០,០០០ដុល្លារអាមេរិក តែប៉ុណ្ណោះ។ ដោយសារតែA គ្មានជម្រើស ព្រោះត្រូវការលុយជាបន្ទាន់នោះក៏ត្រូវបានបង្ខំចិត្តលក់ទៅអោយB ទៅ។

យោងតាមឧទាហរណ៍ខាងលើនេះ យើងឃើញថា B ឆ្លៀតក្នុងឱកាសដែលភាគីម្ខាងទៀតមានការលំបាកខ្លាំង គ្មានជម្រើស ឬ មិនដឹង ឬ ខ្វះបទពិសោធន៍ ដើម្បីបង្កើតកិច្ចសន្យា បានកេងចំណេញយ៉ាងច្រើនសន្ធឹកសន្ធាប់។ ដូចនេះ យើងមិនគួរណាទទួលស្គាល់កិច្ចសន្យាបែបនេះឡើយ។ ការកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ មានទស្សនៈមួយបានលើកឡើងថា វាលើសពី៥០ភាគរយនៃតម្លៃដើម។ ដូចនេះភាគីដែលគេងចំណេញពីកិច្ចសន្យាលើពី ៥០ភាគរយ នៃតម្លៃដើម មិនគួរទទួលស្គាល់កិច្ចសន្យានោះឲ្យមានសុពលភាពឡើយ។

### ១.២.២.ភាពខ្វះសមត្ថភាពរបស់ភាគី

ជាគោលការណ៍ រូបវន្តបុគ្គលទាំងឡាយ នៅពេលដែលមានរូបរាង និងធ្វើទំនាក់ទំនងក្នុងសង្គម នឹងបង្កើតជាសិទ្ធិ និងកាតព្វកិច្ច ដែលជាលក្ខខណ្ឌតម្រូវតាមច្បាប់ ហើយដើម្បីអាចឲ្យសកម្មភាពនោះបង្កើតឡើងនូវសិទ្ធិ និងកាតព្វកិច្ច លុះត្រាច្បាប់ទទួលស្គាល់ថា ជាបុគ្គលមានសមត្ថភាព។ សមត្ថភាពតាមផ្លូវច្បាប់

ដែលមានកំណត់ដោយនីតិរដ្ឋប្បវេណីមាន៣ គឺ សមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព ក្នុងនោះ ការលុបចោលកិច្ចសន្យាដោយមូលហេតុខ្វះសមត្ថភាពភាពរបស់ភាគី មានតែ ២ ប៉ុណ្ណោះ គឺ ១.២.២.១.សមត្ថភាពខាងឆន្ទៈ និង ១.២.២.២.សមត្ថភាពក្នុងការធ្វើសកម្មភាព។

**១.២.២.១.ការខ្វះសមត្ថភាពខាងឆន្ទៈ**

សមត្ថភាពខាងឆន្ទៈ គឺជាសមត្ថភាពដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ ឆន្ទៈរបស់ភាគីពិតជាចាំបាច់ណាស់ក្នុងការបង្កើតកិច្ចសន្យា ឬដែលនាំឲ្យមានការបង្កើតកិច្ចសន្យា ហេតុនេះកិច្ចសន្យាដែលភាគីបានបង្កើតឡើងនៅពេលខ្លួនខ្វះសមត្ថភាពខាងឆន្ទៈ អាចលុបចោលបាន។[16]

ជនដែលខ្វះសមត្ថភាពខាងឆន្ទៈ គឺជាជនដែលមានស្ថានភាពដូចមានចែងក្នុងមាត្រា១៤ នៃក្រមរដ្ឋប្បវេណី ដែលអាចជានីតិជនដែលស្ថិតក្នុងស្ថានភាពស្រវឹង មនុស្សចាស់ជរា(វង្វេង ភ្លេចភ្លាំងច្រើន)ជាដើម។

ឧទាហរណ៍៖ A បានធ្វើកិច្ចសន្យា បានធ្វើកិច្ចសន្យាទិញទំនិញ ដែលមានតម្លៃថ្លៃ របស់ខ្លួនឲ្យទៅមិត្តភក្តិរបស់គាត់ គឺ B នៅពេលដែលគាត់កំពុងស្ថិតក្នុងស្ថានភាពស្រវឹងស្រាជោគជាំ។

ក្នុងឧទាហរណ៍ខាងលើនេះ A បានធ្វើកិច្ចសន្យានៅពេលដែលខ្លួនខ្វះសមត្ថភាពខាងឆន្ទៈ ដូចនេះគាត់អាចលុបចោលកិច្ចសន្យានេះបាន។

**១.២.២.២.ការខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព**

សមត្ថភាពក្នុងការធ្វើសកម្មភាព ជាសមត្ថភាពដែលអាចធ្វើសកម្មភាពដោយមានសុពលភាពពេញលេញ។ ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់បុគ្គល ៣ប្រភេទ ជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពដែលរួមមាន ក.អនីតិជន ខ.ជននៅក្រោមអាណាព្យាបាលទូទៅ និង គ.ជនស្ថិតនៅក្រោមហិតូបត្ថម្ភ។[17] ពោលគឺជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើកិច្ចសន្យាសុពល។

ក.អនីតិជន

អនីតិជន គឺសំដៅទៅលើជនដែលមានអាយុក្រោម១៨ឆ្នាំ។[18] អាយុនីតិភាព ត្រូវបានកំណត់តាមរយៈទន្សនៈទូទៅក្នុងសង្គមអាស្រ័យលើប្រទេសនីមួយៗ ហើយនៅប្រទេសកម្ពុជាយើងបានកំណត់យកបុគ្គលដែលមានអាយុគ្រប់១៨ឆ្នាំ ជានីតិជន។ អនីតិជន ត្រូវស្ថិតនៅក្រោមរបបអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដូចនេះសកម្មភាពដែលអនីតិជនធ្វើដោយពុំមានការយល់ព្រមពីអ្នកមានសិទ្ធិ

---

[16]មាត្រា១៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[17] មាត្រា១៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[18]មាត្រា១៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោលបាន។[19] អ្នកមានសិទ្ធិអំណាចមេបាអាចជាឪពុកម្តាយ ឪពុក ឬម្តាយ ឬឪពុកម្តាយចិញ្ចឹម។[20] ចំណែកឯអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវចាប់ផ្តើមនៅពេលដែលគ្មានអ្នកអនុវត្តសិទ្ធិអំណាចមេបាសម្រាប់អនីតិជន។[21] ប្រព័ន្ធនេះបង្កើតឡើងគឺដើម្បីការពារអនីតិជន ព្រោះថាកម្រិតនៃការយល់ដឹង ឬផ្នែកបញ្ញាស្មារតីរបស់អនីតិជន គឺពុំទាន់ពេញលេញ ដែលអាចនាំឲ្យខ្លួនបង្កើតកិច្ចសន្យាណាមួយដែលធ្វើឲ្យខាតបង់ប្រយោជន៍របស់អនីតិជន។ ទោះបីជាយ៉ាងណាក៏ដោយនេះគ្រាន់តែជាការកំណត់អាយុនីតិភាពប៉ុណ្ណោះ ហើយពិតជាក់ស្តែង អនីតិជនមិនប្រាកដថាសុទ្ធតែមានការយល់ដឹងនៅមានកម្រិតនោះទេ ដូច្នេះហើយ ក្រមរដ្ឋប្បវេណីក៏បានលើកលែងនូវសកម្មភាពមួយចំនួន ដែលអនីតិជនអាចធ្វើបានដោយពុំចាំបាច់មានការយល់ព្រមពីអ្នកតំណាងដែលច្បាប់កំណត់ដែលរួមមាន៖ សកម្មភាពដែលទទួលសិទ្ធិ ការឲ្យរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ពោលគឺអាចធ្វើកិច្ចសន្យាដោយមានសុពលភាពពេញលេញ។ សូមលើកយកឧទាហរណ៍មួយចំនួនដូចខាងក្រោម៖

ឧទារហរណ៍ទី១៖ អនីតិជន A អាយុ១៣ឆ្នាំ បានធ្វើកិច្ចសន្យាលក់ទិញទូរស័ព្ទដែលមានតម្លៃ ១,000 ដុល្លារអាមេរិក ជាមួយម្ចាងហាងទូរស័ព្ទមួយកន្លែង។ ក្រោយមក ឪពុកម្តាយរបស់អនីតិជន A បានដឹង និងចង់លុបចោលកិច្ចសន្យា។

ក្នុងករណីនេះ ឪពុកម្តាយរបស់អនីតិជន A អាចបង្ហាញឆន្ទៈលុបចោលកិច្ចសន្យាបានដោយយកមូលហេតុខ្វះសមត្ថភាពរបស់អនីតិជន A ហើយឪពុកម្តាយជាអ្នកមានសិទ្ធិអំណាចមេបារបស់ A។

ឧទាហរណ៍ទី២៖ករណីទទួលសិទ្ធិ

A ជាអនីតិជន។ B ជាជីតារបស់ A មានភាគហ៊ុនចំនួន៤0% នៅក្នុងក្រុមហ៊ុនលក់សំលៀកបំពាក់។ គាត់បានធ្វើប្រទានកម្មភាគហ៊ុនរបស់គាត់១0% នោះបើ A យល់ព្រមទទួលយក។ ហើយ A អាចយល់ព្រមទទួលយកភាគហ៊ុននោះបានដោយខ្លួនឯង ដោយមិនចាំបាច់ទទួលបានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបារបស់ A ទេ។ ដូចនេះ ការបង្ហាញឆន្ទៈរបស់ A មានសុពលភាព។

ឧទាហរណ៍ទី៣៖ករណីឲ្យរួចផុតពីកាតព្វកិច្ច

A មានអាយុ១៦ឆ្នាំ ជាសន្តតិជនតែម្នាក់របស់ B។ មត៌កជាទ្រព្យសកម្មរបស់ B មានម៉ូតូមួយគ្រឿង ផ្ទះពីរល្វែង។ ចំណែកទ្រព្យអកម្ម គឺ B បានជំពាក់បំណុល C ដែលជាបងប្រុសរបស់ខ្លួនចំនួន ១,000ដុល្លារអាមេ

[19]មាត្រា១៨ កថាខណ្ឌ១ វាក្យខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២00៧

[20]មាត្រា១0៣៥-១0៣៦, ១0៣៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២00៧

[21]មាត្រា១0៣៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២00៧

រិក។ D ត្រូវបានតុលាការចាត់តាំងឲ្យធ្វើជាអ្នកអាណាព្យាបាលសម្រាប់ A។ C បានសម្រេចចិត្តមិនទាមទារយកបំណុលដែល B បានខ្ចីពីខ្លួនវិញទេ ព្រោះយល់ថា A ជាក្មួយរបស់ខ្លួន។

ករណីបែបនេះ គឺជាការលើកលែងឲ្យរួចផុតពីកាតព្វកិច្ច និងមិនចាំបាច់មានការយល់ព្រមពី D ដែលជាអ្នកអាណាព្យាបាលសម្រាប់A ទេ។

ឧទាហរណ៍ទី៤៖ករណីទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។

A ជាក្មេងស្រីអាយុ១២ឆ្នាំ រស់នៅជាមួយឪពុកម្តាយ។ ឪពុកម្តាយរបស់ A បានឲ្យប្រាក់ទៅ A ចំនួន ១០០០០រៀល សម្រាប់ចាយវាយទៅសាលារៀន។ A អាចយកលុយនោះទៅទិញរបស់ញ៉ាំដែលគេចង់ញ៉ាំដូចជា៖ ការ៉េម ឬ នំផ្សេងៗ ដោយមិនចាំបាច់ទៅសុំការអនុញ្ញាតពីឪពុកម្តាយរបស់គេសិនទេ។ កិច្ចសន្យាដែលកុមារី A ធ្វើកិច្ចសន្យាជាមួយអ្នកលក់ការ៉េម ឬអ្នកលក់នំ ជាកិច្ចសន្យាសុពលមានសុពលភាព ទោះបីជាកុមារី A ស្ថិតក្នុងប្រភេទនៃជនដែលត្រូវបានកម្រិតសមត្ថភាពក៏ដោយ ព្រោះថាសកម្មភាពនេះ គឺទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃតែប៉ុណ្ណោះ។

ទន្ទឹមនឹងនេះ អនីតិជនក៏អាចធ្វើកិច្ចសន្យាសុពលភាពពេញលេញបានផងដែរ ក្នុងករណីដែលអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលបានផ្តល់ទ្រព្យសម្បត្តិ និងអនុញ្ញាតឲ្យចាត់ចែងក្នុងទំហំនៃគោលបំណងដែលបានកំណត់ ឬទោះបីមិនបានកំណត់ក៏ដោយ ដូចមានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ យ៉ាងដូច្នេះថា "អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឲ្យចាត់ចែង ដោយកំណត់គោលបំណងក្នុងទំហំគោលបំណងនេះបាន។ ម្យ៉ាងទៀត អនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឲ្យចាត់ចែងដោយមិនបានកំណត់គោលបំណងបានដែរ"។[22]

ឧទាហរណ៍៖ A ជាអនីតិជនអាយុ ៩ឆ្នាំ ម្តាយរបស់ A បានឲ្យទៅ ៤០,០០០រៀល ក្នុងនោះ ២៥,០០០ រៀល សម្រាប់ទិញសៀវភៅ និងសម្ភារសិក្សា ចំណែក ១៥ ០០០រៀលទៀត មិនបានកំណត់ថាសម្រាប់ប្រើធ្វើអ្វីឡើយ។ ករណីនេះ កិច្ចសន្យាដែល A បានបង្កើតក្នុងការទិញសៀវភៅ និងសម្ភារសិក្សាដែលមានតម្លៃ ២៥,០០០រៀល ជាកិច្ចសន្យាសុពល ចំណែកប្រាក់ដែលនៅសល់ A អាចចាត់ចែងដោយឯករាជ្យក្នុងទំហំដែលអាចបង់បានដោយប្រាក់ ១៥,០០០រៀលនោះ។

[22]មាត្រា១៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

គួរបញ្ជាក់ផងដែរថា អនីតិជនក៏ត្រូវបានអនុញ្ញាតឲ្យប្រកបអាជីវកម្មដោយឯករាជ្យបានដែរដោយបានទទួលការអនុញ្ញាតពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដូចមានបញ្ជាក់លម្អិតខាងក្រោម។

ក្នុងករណីដែលមានការទទួលស្គាល់ពីអាណាព្យាបាល (អ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន) ឲ្យប្រកបអាជីវកម្មដោយឯករាជ្យបាន (មាត្រា១០៤៦ និង១០៧៩) ទោះបីជាអនីតិជនក៏ដោយ ក៏មានសមត្ថភាពក្នុងការធ្វើកិច្ចសន្យាចាំបាច់សម្រាប់អាជីវកម្មនោះបានដែរ។ ប្រសិនជាមានការអនុញ្ញាតឲ្យប្រកបអាជីវកម្មដោយឯករាជ្យ តែរាល់ពេលទិញទំនិញចូល ឬពេលជួលបុគ្គលិកជាដើម សុទ្ធតែត្រូវទទួលការយល់ព្រមពីអ្នកអាណាព្យាបាល ការអនុញ្ញាតឲ្យប្រកបអាជីវកម្មមិនសូវមានន័យទៅវិញ។

ប្រសិនបើអ្នកមានអំណាចមេបាជាដើម បានអនុញ្ញាតឲ្យអនីតិជនប្រកបអាជីវកម្ម ដោយយល់ឃើញថា មានភាពចាស់ទុំដែរ ប៉ុន្តែជាការច្រឡំថា អនីតិជនបែរជាយកដើមទុនសម្រាប់ការរកទទួលទានទៅលេងល្បែងស៊ីសង ឬទិញតែទំនិញដែលលក់មិនដាច់ ហើយខាតរាល់ដងជាដើម ក្នុងករណីនេះ អ្នកមានអំណាចមេបាជាដើមនោះ អាចលុបចោល ឬកម្រិតនូវការអនុញ្ញាតដែលខ្លួនបានផ្តល់រួចហើយនោះបាន (កថាខណ្ឌទី២ នៃមាត្រា២០)។

ប៉ុន្តែបើគ្រាន់តែជាការផ្លាស់ប្តូរនូវឆន្ទៈអញ្ចឹងភាពរបស់អ្នកមានអំណាចមេបាជាដើម មិនអាចលុបចោល ឬកម្រិតបានទេ។ ពេលណាលុបចោលនូវការអនុញ្ញាតនោះទៅ សមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អនីតិជននោះនឹងត្រឡប់ទៅស្ថានភាពដើមវិញ។ បញ្ញត្តិនៃមាត្រានេះក៏មិនអាចអនុវត្តដែរ ចំពោះករណីដែលអនីតិជនជាអ្នកនៅក្រោមអាណាព្យាបាលទូទៅ។ ក្នុងករណីដែលអនីតិជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅច្បាស់ជាមិនមានការអនុញ្ញាតឲ្យមានការប្រកបអាជីវកម្មឡើយ ប៉ុន្តែទោះជាមានក៏ដោយ ក៏បញ្ញត្តិស្តីពីអាណាព្យាបាលទូទៅ ត្រូវយកមកអនុវត្តដែរ ហើយសកម្មភាពរបស់អនីតិជនដែលនៅក្រោមអាណាព្យាបាលទូទៅទោះបីជាសកម្មភាពនោះស្ថិតក្នុងទំហំនៃការអនុញ្ញាតឲ្យធ្វើអាជីវកម្មក៏ដោយ ក៏អាចលុបចោលសកម្មភាពបានដែរ (មាត្រា២៦)។[23]

លើសពីនេះ ក្រមរដ្ឋប្បវេណីទទួលស្គាល់ថា អនីតិដែលទទួលអត្តាធីនភាព ត្រូវបានចាត់ទុកថាបានដល់នីតិភាព ដូចនេះយើងអាចបកស្រាយបានថា កិច្ចសន្យាដែលធ្វើឡើងដោយអនីតិជនដែលទទួលអត្តាធីនភាព មានសុពលភាពដូចកិច្ចសន្យាដែលធ្វើឡើងដោយនីតិជនដែលមានសមត្ថភាពពេញលេញដែរ។[24]

[23]សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១, កំណត់មាត្រា២០

[24]មាត្រា២២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អត្តាធីនភាព សំដៅលើស្ថានភាពមួយ ដែលផ្តល់ឲ្យអនីតិជនបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬរួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ។

ក្រមរដ្ឋប្បវេណីកំណត់ពីលក្ខខណ្ឌអនីតិជនអាចទទួលបានអត្តាធីនភាពមាន ២ ស្ថានភាព ដូចខាងក្រោម៖

ស្ថានភាពទី១៖ អនីតិជនដែលបានដល់អាយុ ១៦ឆ្នាំ ហើយអាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ និងទទួលបានការប្រកាសទទួលស្គាល់ពីតុលាការតាមពាក្យសុំរបស់អនីតិជននោះ។[25]

ស្ថានភាពទី២៖ អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ។ ចំពោះអនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ គឺទទួលបានអត្តាធីនភាពដោយស្វ័យប្រវត្តិ ដោយពុំចាំបាច់មានការប្រកាសទទួលស្គាល់ពីតុលាការនោះទេ។[26]

ជាគោលការណ៍ អនីតិជន ជាជនដែលមិនទាន់ដល់នីតិភាព និងមិនទាន់អាចរៀបអាពាពិពាហ៍បានឡើយ ព្រោះថាអាយុអប្បបរមាដែលសមរម្យសម្រាប់រៀបអាពាហ៍ពិពាហ៍ គឺអាយុ ១៨ឆ្នាំ ដែលជាអាយុដល់នីតិភាព ប៉ុន្តែយោងតាមស្ថានភាពក្នុងសង្គម ជាពិសេសនៅតាមតំបន់ជនបទ យើងឃើញមានអនីតិជនជាច្រើនរៀបអាពាហ៍ពិពាហ៍ ដូចនេះហើយទើបច្បាប់តម្រូវឲ្យមានលក្ខខណ្ឌ ៣ ទើបអនីតិជនអាចរៀបអាពាហ៍ពិពាហ៍បានរួមមាន៖ (១) អនីតិជននោះត្រូវមានអាយុមិនតិចជាង១៦ឆ្នាំ (២) ភាគីម្ខាងទៀតជានីតិជន និង (៣) ទទួលបានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ។

ក្នុងករណីខាងលើ ទោះបីជាអនីតិជនដែលបានទទួលអត្តាធីនភាព ដោយអង្គហេតុរៀបអាពាហ៍ពិពាហ៍ បានលែងលះគ្នាក៏ដោយ ក៏អត្តាធីនភាពមិនរលត់ដែរ។[27]

មួយវិញទៀត ពាក់ព័ន្ធនឹងកិច្ចសន្យាការងាររបស់អនីតិជន អ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជននោះបានទេ លើកលែងតែអនីតិជននោះផ្តល់សច្ចានុមតិលើកិច្ចសន្យាការងារនោះ។ នៅក្នុងករណីដែលយល់ឃើញថាកិច្ចសន្យាការងាររបស់អនីតិជន អាចធ្វើឲ្យខូចប្រយោជន៍របស់អនីតិជននោះ អ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬស្ថាប័នរដ្ឋបាល អាចរំលាយកិច្ចសន្យាការងារនោះឆ្ពោះទៅអានាគតបាន។[28]

ខ.ជននៅក្រោមអាណាព្យាបាលទូទៅ

[25]មាត្រា២១ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[26]មាត្រា២១ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[27]មាត្រា២១ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[28]មាត្រា២៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតក្នុងស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី និងដែលត្រូវបានតុលាការប្រកាសរបបអាណាព្យាបាលទូទៅតាមពាក្យសុំរបស់អ្នកដែលមានសិទ្ធិដាក់ពាក្យសុំ។[29] អ្នកដែលអាចដាក់ពាក្យសុំឲ្យតុលាការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅមានដូចជា សាមីខ្លួន សហព័ន្ធរបស់ជននោះ ញាតិដែលស្ថិតនៅក្នុង៤ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។[30] ការដាក់ពាក្យស្នើសុំទៅតុលាការឲ្យប្រកាសរបបអាណាព្យាបាលទូទៅ មិនអាចធ្វើបានឡើយប្រសិនបើសាមីខ្លួនមានអាយុក្រោម ១៥ឆ្នាំ នៅពេលដែលមានពាក្យសុំ។[31] មានន័យថា ប្រសិនបើអនីតិជនដែលមានអាយុមិនទាន់ដល់ ១៥ឆ្នាំ ហើយមានស្ថានភាពដូចជននៅក្រោមអាណាព្យាបាលទូទៅ (មានបញ្ហាខាងផ្នែកបញ្ញាស្មារតី និងខាងផ្លូវចិត្ត) អនីតិជននោះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងថែរក្សា និងត្រួតពិនិត្យរបស់អ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។ លុះដល់ពេលអនីតិជននោះអាយុ ១៥ឆ្នាំឡើងទៅ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់ជននោះ អាចដាក់ពាក្យសុំទៅតុលាការដើម្បីប្រកាសរបបអាណាព្យាបាលទូទៅចំពោះជនដែលជាអនីតិជននោះ។ ករណីនេះបានន័យថា អនីតិជននោះស្ថិតនៅក្រោម អាណាព្យាបាលសម្រាប់អនីតិជនផង និងជាជននៅក្រោមអាណាព្យាបាលទូទៅផង។ ម្យ៉ាងវិញទៀតយើងឃើញថាអ្នកដែលមានសិទ្ធិដាក់ពាក្យសុំឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ក្នុងនោះមានហិតូបត្ថម្ភកៈផងដែរ។ ស្ថានភាពនេះកើតឡើងចំពោះជនដែលត្រូវបានប្រកាសរបបហិតូបត្ថម្ភរួចហើយ ក្រោយមកវិបត្តិផ្នែកបញ្ញាស្មារតីរបស់ជននោះមានស្ថានភាពកាន់តែធ្ងន់ធ្ងរ ដូចនេះហិតូបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ អាចដាក់ពាក្យសុំទៅតុលាការដើម្បីប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ។ ឆ្លើយតបទៅនឹងចំណុចនេះ ដើម្បីជៀសវាងនូវទំនាក់ទំនងគតិយុត្តដ៏ស្មុគស្មាញមួយ ប្រសិនបើជននោះស្ថិតនៅក្រោមរបបហិតូបត្ថម្ភផង និងរបបអាណាព្យាបាលទូទៅផង តុលាការត្រូវប្រកាសលុបចោលការប្រកាសការចាប់ផ្តើមហិតូបបត្ថម្ភចំពោះជននោះ ដូចនេះជននោះក្លាយជាជនដែលស្ថិតនៅក្រោមអាណាព្យាបាលទៅវិញ។[32]

[29]មាត្រា២៤ កថាខណ្ឌ១ វាក្យខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[30]មាត្រា២៤ កថាខណ្ឌ១ វាក្យខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[31]មាត្រា២៤ កថាខណ្ឌ១ វាក្យខណ្ឌ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[32]មាត្រា២៤ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដោយសារតែជននៅក្រោមអាណាព្យាបាលទូទៅ ជាជនដែលមានបញ្ហាផ្នែកបញ្ញាស្មារតីធ្ងន់ធ្ងរ ដូចនេះ ជននៅក្រោមអាណាព្យាបាលទូទៅពុំអាចធ្វើសកម្មភាពដោយឯករាជ្យនោះទេ។ រាល់សកម្មភាពដែលធ្វើឡើងដោយជននៅក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបាន ព្រោះថាសកម្មភាពនោះធ្វើឡើងដោយជនខ្វះសមត្ថភាព លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃតែប៉ុណ្ណោះ ដែលច្បាប់មិន ផ្តល់សិទ្ធិលុបចោល។[33] សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ គឺជាសកម្មភាពពាក់ព័ន្ធនឹងការរស់នៅរាល់ថ្ងៃ ដូចជាការទិញរបស់ប្រើប្រាស់ប្រចាំថ្ងៃ ការទិញនំចំណីជាដើម។[34] យើងអាចបកស្រាយបានថា បើត្រឹមតែជាសកម្មភាពដែលធ្វើឡើងបម្រើផលប្រយោជន៍ឲ្យការរស់នៅប្រចាំថ្ងៃ ជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើបាន និងជាកិច្ចសន្យាសុពល ព្រមទាំងពុំអាចធ្វើការលុបចោលបានទេ។ ច្បាប់បញ្ញត្តិបែបនេះ ព្រោះគិតទៅដល់សុវត្ថិភាពនៃកិច្ចការជំនួញរបស់ភាគីម្ខាងទៀត នៃកិច្ចការជួញដូរពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ ម្យ៉ាងទៀតក៏បង្កភាពងាយស្រួលដល់ជននៅក្រោមអាណាព្យាបាលទូទៅ ក្នុងការទិញរបស់របរប្រើប្រាស់ប្រចាំថ្ងៃដោយខ្លួនឯងបាន។

ខាងក្រោមនេះ ជាឧទាហរណ៍ខ្លះៗដែលធ្វើឡើងដោយភាគីម្ខាងជាជននៅក្រោមអាណាព្យាបាលទូទៅ។

ឧទាហរណ៍ទី១៖ A ត្រូវបានតុលាការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ។ ក្រោយមកគាត់បានទិញខោមួយដែលមានតម្លៃ១០ដុល្លារអាមេរិក។ កិច្ចសន្យានេះ មិនអាចលុបចោលបានទេ ព្រោះជាអញ្ញត្រកម្មនៃច្បាប់ ដោយលើកលែងករណីដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ជាកិច្ចសន្យាសុពល។

ឧទាហរណ៍ទី២៖ A ជាជននៅក្រោមអាណាព្យាបាលទូទៅ។ គាត់បានចុះកិច្ចសន្យាប្រទានកម្មលុយ ១,០០០ដុល្លារអាមេរិក អោយទៅ B ដែលជាអ្នកជិតខាងផ្ទះ។ កិច្ចសន្យានេះ អាចលុបចោលបាន ព្រោះធ្វើឡើងដោយជនខ្វះសមត្ថភាព។

នៅពេលដែលសមត្ថភាពខាងឆន្ទៈ ក៏ដូចជាការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនមានភាពល្អប្រសើរឡើងវិញ នោះតុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ន្ធ ញាតិដែលស្ថិតក្នុងបួនថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអាណាព្យាបាល មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។[35] ក្រោយការ

[33]មាត្រា២៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[34]សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១, កំណត់មាត្រា២៦

[35]មាត្រា២៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ប្រកាសលុបចោលរបបអាណាព្យាបាលទូទៅ ជននោះត្រូវបានក្លាយជាជនមានសមត្ថភាពឡើងវិញ និងអាចធ្វើកិច្ចសន្យាសុពលដូចមានសមត្ថភាពដែរ។

គ.ជនស្ថិតនៅក្រោមហិតូបត្ថម្ភ

ជនស្ថិតនៅក្រោមហិតូបត្ថម្ភ គឺជាជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី និងដែលត្រូវបានតុលាការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ តាមពាក្យសុំរបស់អ្នកដែលមានសិទ្ធិដាក់ពាក្យសុំ។ អ្នកដែលមានសិទ្ធិដាក់ពាក្យសុំទៅតុលាការអោយប្រកាសការចាប់ផ្តើមហិតូបត្ថម្ភមានដូចជា សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង៤ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអាណាព្យាបាល មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។ ចំពោះការដាក់ពាក្យសុំប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ ក៏មានការកំណត់អាយុរបស់សាមីខ្លួនដូចការដាក់ពាក្យសុំប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅដែរ ពោលគឺសាមីខ្លួនត្រូវមានអាយុយ៉ាងតិច ១៥ឆ្នាំ នៅពេលដែលមានពាក្យសុំ។

ជាគោលការណ៍ សកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភធ្វើ ត្រូវតែមានការយល់ព្រមពីហិតូបត្ថម្ភកៈ លើកលែងតែសកម្មភាពទាក់ទងនឹងជីវភាពប្រចាំថ្ងៃប៉ុណ្ណោះ។ ក្រមរដ្ឋប្បវេណីក៏មានចែងអំពីសកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភធ្វើ ដោយពុំមានការយល់ព្រមពីហិតូបត្ថម្ភកៈ ហើយអាចលុបចោលបាន មានដូចខាងក្រោម៖[36]

- ការទទួល ឬប្រើប្រាស់ប្រាក់ទុន (ឧទាហរណ៍ដូចជា៖ ការដកប្រាក់ពីគណនីបញ្ញើ ការទទួលនូវសំណងនៃបំណុល ការអោយគេខ្ចីប្រាក់)
- ការខ្ចីទ្រព្យ ឬការធានា
- ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬធ្វើអោយបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត
- ការធ្វើសកម្មភាពបណ្តឹង
- ការធ្វើប្រទានកម្ម ឬធ្វើកិច្ចសន្យាស្រុះស្រួល ឬកិច្ចសន្យាមជ្ឈត្តិកម្ម
- ការទទួលស្គាល់នូវសន្តតិកម្ម ឬការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬការបែងចែងនូវមរតក
- ការប្រកែកមិនទទួលប្រទានកម្ម ឬអច្ច័យទាន ឬការយល់ព្រមទទួលនូវប្រទានកម្ម ឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក

[36]មាត្រា៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬការជួសជុលធំៗ
- ការធ្វើភតិសន្យាដែលមានអំឡុងពេលលើសពី៣ឆ្នាំចំពោះដីធ្លី លើសពីឆ្នាំចំពោះអាគារ លើសពី៦ខែចំពោះចលនវត្ថុ
- សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ តាមពាក្យសុំរបស់ជនដែលមានសិទ្ធិដាក់ពាក្យសុំទៅតុលាការដើម្បីប្រកាសការចាប់ផ្តើមរបបហិតូបត្ថម្ភ ឬហិតូបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យ ហិតូបត្ថម្ភកៈ។

គួរបញ្ជាក់ផងដែរថា ហិតូបត្ថម្ភកៈ មិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ទេ ដោយហេតុថា សិទ្ធិអំណាចរបស់ហិតូបត្ថម្ភកៈ គឺជាការផ្តល់នូវការយល់ព្រមចំពោះសកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភមិនអាចធ្វើឡើងដោយឯករាជ្យបាន មិនមែនជាការផ្តល់សិទ្ធិអំណាចអោយធ្វើជាអ្នកតំណាងសាមីខ្លួន ដូចអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលទេ។

ដូចបានរៀបរាប់ខាងលើរួចហើយថា ក្រមរដ្ឋប្បវេណីចាត់ទុកជននៅក្រោមហិតូបត្ថម្ភ ជាជនមួយប្រភេទដែលត្រូវបានកម្រិតសមត្ថភាព ដោយយកមូលហេតុនៃការកង្វះនូវសមត្ថភាពខាងឆន្ទៈ និងមានបញ្ហាផ្នែកបញ្ញាស្មារតី ដូចនេះនៅពេលដែលស្ថានភាពនៃការយល់ដឹងទាក់ទងនឹងផ្នែកស្មារតីរបស់ជននៅក្រោមហិតូបត្ថម្ភមានភាពល្អប្រសើរឡើងវិញ នោះក៏ពុំមានភាពចាំបាច់អីដែលត្រូវបន្តទុកជននោះអោយស្ថិតនៅក្រោមរបបហិតូបត្ថម្ភកៈទៅទៀតដែរ ក្នុងករណីនេះតុលាការត្រូវលុបចោលនូវការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភតាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតក្នុង៤ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។[37] នៅពេលដែលតុលាការប្រកាសលុបចោលការចាប់ផ្តើមហិតូបត្ថម្ភ បានន័យថា ជននៅក្រោមហិតូបត្ថម្ភបានរួចផុតពីការនៅក្រោមរបបហិតូបត្ថម្ភ ហើយលែងជាជនត្រូវបានកម្រិតសមត្ថភាពទៀតហើយ ព្រមទាំងអាចធ្វើកិច្ចសន្យាសុពលដូចជនមានសមត្ថភាពដែរ។

[37]មាត្រា៣១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី២

# អ្នកមានសិទ្ធិលុបចោល និងការផ្ដល់សច្ចានុមតិ

## ២.១.អ្នកមានសិទ្ធិលុបចោល និងការផ្ដល់សច្ចានុមតិ

ចំពោះកិច្ចសន្យាដែលអាចលុបចោលបាន មិនមែននរណាក៏អាចប្រកាសលុបចោលកិច្ចសន្យាបាននោះទេ ព្រោះកិច្ចសន្យាដែលមានមូលហេតុអាចលុបចោល គ្មានអានុភាពប៉ះពាល់ដល់សង្គមទាំងមូលទេ។ ដូច្នេះ ក្រមរដ្ឋប្បវេណីបានកំណត់យ៉ាងច្បាស់ពីអ្នកដែលមានសិទ្ធិលុបចោលទៅតាមមូលហេតុដែលនាំឲ្យកិច្ចសន្យាអាចលុបចោលបាន។ រីឯអ្នកដែលមានសិទ្ធិផ្ដល់សច្ចានុមតិក៏ត្រូវបានកំណត់ច្បាស់ដូចគ្នាផងដែរ។

### ២.១.១.អ្នកមានសិទ្ធិលុបចោលកិច្ចសន្យាដែលមានវិការៈ

អ្នកដែលមានសិទ្ធិលុបចោលសកម្មភាពដែលអាចលុបចោលបាន ដោយយោងលើមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈដូចមានចែងចាប់ពីមាត្រា៣៤៦ ដល់មាត្រា៣៥១ មានដូចជា៖

- អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬ
- អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះប្រសិនបើមាន ឬ
- សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ ឬ
- អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកបង្ហាញឆន្ទៈ
- អច្ច័យលាភីសកលពីអ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ (មាត្រា១២១២)។

អ្នកតំណាងដែលច្បាប់បានកំណត់សំដៅទៅលើអ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកអាណាព្យាបាលទូទៅប៉ុណ្ណោះ។ ចំពោះហិតូបត្ថម្ភកៈវិញ មិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ទេ ព្រោះហិតូបត្ថម្ភកៈមានតួនាទីគ្រាន់តែផ្ដល់ការយល់ព្រមទៅលើសកម្មភាពរបស់អ្នកនៅក្រោមហិតូបត្ថម្ភប៉ុណ្ណោះ។[38]

ជាការគួរឲ្យកត់សម្គាល់មួយទៀត គឺនៅក្នុងមាត្រា៣៥៩ មិនបានចែងពីអច្ច័យលាភីសកលពីអ្នកដែលបង្ហាញឆន្ទៈមានវិការៈទេ តែបើក្រលេកមើលពីគោលគំនិតនៃមាត្រា១២១២ អច្ច័យលាភីសកល ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។[39]

[38]មាត្រា៣១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[39]មេរៀនភាគ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៧, ២០១៦

ឧទាហរណ៍៖ A បានធ្វើកិច្ចសន្យាខ្ចីប្រើ ជាមួយ B ហើយបានឲ្យម៉ូតូរបស់ខ្លួនទៅ A ខ្ចីដោយសារការ ឆបោករបស់ B ក្រោយមក A បានទទួលមរណភាព។ បើ A បានធ្វើអច្ច័យទានសកលទ្រព្យសម្បត្តិរបស់ខ្លួនឲ្យទៅ C នោះ C ក៏អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យាខ្ចីប្រើ ដោយយោងលើការឆបោកនោះបានដែរ។

ឧទាហរណ៍៖ A បានបង្ហាញឆន្ទៈធ្វើកិច្ចសន្យាខ្ចីប្រើ ជាមួយ B ដោយសារ B បានគម្រាងកំហែង A។ ករណីបែបនេះ A អាចលុបចោលកិច្ចសន្យានេះបាន។ ម្យ៉ាងទៀតបើ A ជាអនីតិជន ហើយ C ជាអ្នកមានអំណាចមេបាលើ A នោះ C អាចលុបចោលកិច្ចសន្យា ដោយយោងលើមូលហេតុនៃការឆបោកបាន។

ម្យ៉ាងវិញទៀតផងដែរ ប្រសិបបើ A បានទទួលមរណភាព ហើយមាន D ជាសន្តតិជនតែម្នាក់ នោះ D អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យានោះបាន។ ករណីមួយទៀត ប្រសិនបើ A បានធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យាដូចមានចែងក្នុងមាត្រា៥១២ ឲ្យទៅ Z នោះ Z ក៏អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យានោះបាន ដែរ ។

## ២.១.២.អ្នកមានសិទ្ធិលុបចោលកិច្ចសន្យាធ្វើឡើងដោយខនខ្វះសមត្ថភាព

ពាក្យសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ដែលមានចែងក្នុងមាត្រា៣៥៩ កថាខណ្ឌទី២ គឺមានន័យដូចគ្នានឹងពាក្យ សមត្ថភាពខាងឆន្ទៈ ដែលមានចែងនៅក្នុងមាត្រា១៤ ដែរ។[40] អ្នកដែលមានសិទ្ធិលុបចោលចំពោះសកម្មភាពដែលអាចលុបចោលបាន ដោយយោងលើមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ អនីតិភាព ឬការកម្រិតសមត្ថភាពក្នុងការបង្ហាញឆន្ទៈមានដូចជា៖

- អ្នកបង្ហាញឆន្ទៈ
- អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកបង្ហាញឆន្ទៈ
- ហិតូបត្ថម្ភកៈរបស់អ្នកបង្ហាញឆន្ទៈ
- សន្តតិជននៃអ្នកបង្ហាញឆន្ទៈ
- អច្ច័យលាភីសកលរបស់អ្នកបង្ហាញឆន្ទៈ
- អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ(មាត្រា៥១៤នៃក្រមរដ្ឋប្បវេណី។

ជាការកត់សម្គាល់ មាត្រា៣៥៩ មិនបានបញ្ញត្តិពីអ្នកទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈទេ តែបើក្រលេកមើលគោលគំនិតមាត្រា៥១៤ វិញ អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។[41]

[40]មេរៀនភាគ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៧, ២០១៦

[41]មេរៀនភាគ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៨, ២០១៦

ម្យ៉ាងវិញទៀតក៏មានការកំណត់ពិសេសចំពោះ អ្នកដែលត្រូវបានកម្រិតសមត្ថភាព ដោយត្រូវបានផ្តល់សិទ្ធិឲ្យលុបចោលសកម្មភាពដែលអាចលុបចោលដោយសេរី ប៉ុន្តែក្រោយពីបានអនុវត្តសិទ្ធិលុបចោលហើយ ជននោះមិនអាចលុបចោលការអនុវត្តសិទ្ធិលុបចោលនោះវិញបានឡើយ។[42]

ឧទាហរណ៍៖ A ជាអនីតិជន បានធ្វើកិច្ចសន្យាជួលរថយន្តម៉ាក TOYOTA Camryជាមួយ B។ A បានដឹងថាខ្លួនអាចលុបចោលកិច្ចសន្យានោះបាន ព្រោះខ្លួនជាជនត្រូវបានកម្រិតសមត្ថភាពក៏សម្រេចចិត្តលុបចោលកិច្ចសន្យានោះចោល។ ករណីនេះ បើ A ចង់លុបចោល ការលុបចោលកិច្ចសន្យានោះវិញ គឺមិនអាចធ្វើបានទេ។

ជាឧទាហរណ៍មួយទៀត៖ A ជាអនីតិជន បានធ្វើកិច្ចសន្យាទិញទូរស័ព្ទម៉ាក IPHONE ក្នុងតម្លៃ ១,២០០ ដុល្លារអាមេរិក ពីហាងលក់ទូរស័ព្ទមួយកន្លែង។ B ជាអ្នកអាណាព្យាបាលដែលត្រូវបានតុលាការចាត់តាំងរបស់ A នោះ B អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យាទិញទូរស័ព្ទរវាង A និងហាងលក់ទូរស័ព្ទបាន។

ម្យ៉ាងវិញទៀត បើ A ជាជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភដូចមានចែងនៅក្នុងមាត្រា២៨ ហើយបានធ្វើកិច្ចសន្យាខ្ចីបរិភោគនូវប្រាក់ចំនួន ១.០០០ ដុល្លារអាមេរិក ជាមួយ B នោះ ហិតូបត្ថម្ភកៈ ដែលចាត់តាំងដោយតុលាការមានសិទ្ធិលុបចោលសកម្មភាពនោះវិញបាន។

ចំពោះករណីសិក្សាមួយទៀត A បានធ្វើកិច្ចសន្យាលក់ទិញគំនូរបុរាណមួយផ្ទាំងដែលមានតម្លៃ ១០,០០០ ដុល្លារអាមេរិក ដោយពេលធ្វើកិច្ចសន្យានោះ គឺ A ស្ថិតនៅក្នុងសភាពស្រវាំងខ្លាំង បន្ទាប់មក A បានបើររថយន្តជួបគ្រោះថ្នាក់ចរាចរណ៍ដល់បាត់បង់ជីវិតនៅយប់ដដែល។ B ដែលជាសន្តតិជនរបស់ A អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យាលក់ទិញគំនូរបុរាណនោះបាន។ ម្យ៉ាងវិញទៀត បើពេលនៅរស់ A បានធ្វើអច្ច័ទានសកលឱ្យទោ C នោះ C ក៏អាចលុបចោលកិច្ចសន្យានោះបានដូចគ្នា។

### ២.១.៣.អ្នកដែលមានសិទ្ធិផ្តល់សច្ចានុមតិ

សច្ចានុមតិអាចត្រូវបានផ្តល់ដោយអ្នកមានសិទ្ធិលុបចោល។[43] ចំពោះករណីដែលសកម្មភាពដែលអាចលុបចោលបានដោយយោងលើមូលហេតុការបង្ហាញឆន្ទៈមានវិការៈ អ្នកដែលមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន ចាប់តាំងពីពេលដែលអ្នកមានសិទ្ធិលុបចោលនោះបានដឹងពីមូលហេតុនៃការលុបចោល។[44] ចំណែកឯសកម្មភាពដែលអាចលុបចោលបាន ដោយយោងលើមូលហេតុ ជនដែលបានបង្ហាញឆន្ទៈជាជនដែលត្រូវបានកម្រិតសមត្ថភាពវិញនោះ សាមីខ្លួនអាចផ្តល់សច្ចានុមតិបានតែនៅក្រោយពេលដែលស្ថាន

[42]មេរៀនភាគ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៨, ២០១៦

[43]មាត្រា៣៦១ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[44]មាត្រា៣៦១ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

ភាព ដែលត្រូវបានកម្រិតសមត្ថភាពនោះ រលត់ប៉ុណ្ណោះ។ នេះគឺមានភាពខុសគ្នាពីការលុបចោលដែលអនុញ្ញាតឲ្យជនដែលត្រូវបានកម្រិតសមត្ថភាពលុបចោលសកម្មភាពបាន ទោះបីមុនពេលការកម្រិតសមត្ថភាពនោះរលត់ក៏ដោយ។[45] យ៉ាងណាមិញចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលទូទៅ) និងហិតូបត្ថម្ភកៈ អាចផ្តល់សច្ចានុមតិបានទាំងមុនពេលដែលជននោះត្រូវបានរួចផុតពីការកម្រិតសមត្ថភាព និងក្រោយពេលដែលការកម្រិតសមត្ថភាពនោះត្រូវបានរលត់។[46]

ចំណុចគួរពិចារណាមួយគឺ ប្រសិនបើអ្នកដែលបានត្រូវកម្រិតសមត្ថភាព បានទទួលការយល់ព្រមពីហិតីបត្ថម្ភកៈ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ តើគេអាចផ្តល់សច្ចានុមតិបានដែរ ឬយ៉ាងណានោះ នៅក្នុងក្រមមិនបានធ្វើការបញ្ជាក់ឱ្យច្បាស់ទេ។ យ៉ាងណាមិញ បើយោងទៅលើការបកស្រាយមាត្រា១៨ (សិទ្ធិលុបចោលសកម្មភាពរបស់អនីតិជន) មាត្រា២៦ (សិទ្ធិលុបចោលសកម្មភាពរបស់ជននៅក្រោមរបបអាណាព្យាបាលទូទៅ) និងមាត្រា៣០ (សិទ្ធិលុបចោលសកម្មភាពរបស់ជននៅក្រោមរបបហិតូបត្ថម្ភកៈ) អាចត្រូវបានបកស្រាយថា អនីតិជន និងជននៅក្រោមរបរហិតូបត្ថម្ភកៈ បើបានទទួលការយល់ព្រម គឺអាចធ្វើសច្ចានុមតិបាន ចំណែកឯជននៅក្រោមរបបអាណាព្យាបាលទូទៅ ទោះបីជាបានទទួលការយល់ព្រម ឬអត់ ក៏មិនអាចធ្វើសច្ចានុមតិបានដែរ។[47]

## ២.២.របៀបនៃការលុបចោល និងការផ្តល់សច្ចានុមតិ

### ២.២.១.របៀបនៃការលុបចោលកិច្ចសន្យា

ភាគីដែលមានសិទ្ធិលុបចោល គ្រាន់តែជូនដំណឹងអំពីការលុបចោលនោះទៅភាគីម្ខាងទៀតនៃកិច្ចសន្យា ហើយអានុភាពនៃការលុបចោលនឹងត្រូវកើតនៅពេលដែលការជូនដំណឹងនោះបានដល់ភាគីម្ខាងទៀត ទោះបីមិនមានការយល់ព្រមរបស់ភាគីម្ខាងទៀតក៏ដោយ។ មធ្យោបាយនៃការជូនដំណឹងភាគីអាចជ្រើសរើសយក មធ្យោបាយណាក៏បានដែរ ដូចជាតាមរយៈការទូរស័ព្ទទៅប្រាប់ ការផ្ញើសារអេឡិចត្រូនិច ដូចជា Facebook E-mail Line Telegram Viber... ជាដើម។ នៅពេលដែលភាគីប្រើប្រាស់មធ្យោបាយបានជូនដំណឹងតាមរយៈការផ្ញើសារអេឡិចត្រូនិច ភាគីត្រូវប្រាកដថាការជូនដំណឹងរបស់ខ្លួនពិតជាបានទៅដល់ភាគីម្ខាងទៀតមែន ព្រោះការប្រើប្រាស់មធ្យោបាយនេះ អាចមានករណីខ្លះមិនអាចបញ្ជូនដំណឹងទៅភាគីម្ខាងទៀតបាន។ ប៉ុន្តែប្រសិនជាអ្នកបង្ហាញឆន្ទៈលុបចោលអះអាងថាខ្លួនពិតជាបានជូនដំណឹងទៅភាគីម្ខាងទៀត តាមរយៈ

[45]មាត្រា៣៦១ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[46]សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, កំណត់មាត្រា៣៦១

[47]មេរៀនភាគ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ១០ ឆ្នាំ២០១៦

ទូរស័ព្ទ តាមការផ្ញើរសារអេឡិចត្រូនិច ឬ តាមរយៈសំបុត្រហើយ តែភាគីម្ខាងទៀតបដិសេធការអះអាងរបស់អ្នកបង្ហាញឆន្ទៈថាខ្លួនមិនបានទទួលការជូនដំណឹងទេ វានឹងបង្កការពិបាកក្នុងការពិចារណាថាភាគីទៀតបានដឹង ឬ មិនបានដឹងពីការលុបចោលកិច្ចសន្យារបស់អ្នកបង្ហាញឆន្ទៈលុបចោល។ ប៉ុន្តែជៀសវាងករណីមានវិវាទ ភាគីគប្បីប្រើប្រាស់វិធីណាដែលងាយស្រួលបង្ហាញអំពីការជូនដំណឹងដល់ភាគីម្ខាងទៀតដើម្បីទុកជាភស្តុតាង ដូចជាឲ្យភាគីម្ខាងទៀតផ្ដិតមេដៃ ចុះហត្ថលេខា ឬ ថតទុកសារអេឡិចត្រូនិច ដែលបង្ហាញថាភាគីម្ខាងទៀតបានទទួលដំណឹងពិតប្រាកដមែន។ ដើម្បីជាសំអាងបញ្ជាក់កាន់តែច្បាស់ពីការជូនដំណឹងទៅអំពីការបង្ហាញឆន្ទៈទៅកាន់ភាគីម្ខាងទៀតដែលនៅឆ្ងាយ អាចប្រើមធ្យោយបាន "ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល" នៃលិខិតអនុសិដ្ឋដែលមាន "ការផ្តល់ដំណឹងឆ្លើយតបពីការទទួល" និងឯកសារចម្លងនៃលិខិតបានចុះនិទ្ទេសដោយក្រឡាបញ្ជីតុលាការ។[48] ម្យ៉ាងទៀត អ្នកបង្ហាញឆន្ទៈលុបចោលអាចប្រើប្រាស់វិធីណាដែលងាយស្រួលបង្ហាញអំពីការជូនដំណឹងដល់ភាគីម្ខាងទៀត ដើម្បីទុកជាភស្តុតាង ដូចជាឲ្យភាគីម្ខាងទៀតផ្ដិតមេដៃ ចុះហត្ថលេខា ឬ ថតទុកសារអេឡិចត្រូនិចទុក ដែលបង្ហាញថាភាគីម្ខាងទៀតបានទទួលដំណឹងពិតប្រាកដមែន។

### ២.២.២.របៀបនៃការផ្តល់សច្ចានុមតិ

សច្ចានុមតិ គឺជាសកម្មភាពដែលបុគ្គលដែលមានសិទ្ធិលុបចោលកិច្ចសន្យា បានបង្ហាញជាស្ថាពរថាខ្លួនមិនអនុវត្តសិទ្ធិលុបចោលដោយផ្អែកលើបុរេលក្ខខណ្ឌដែលបានដឹងថា សកម្មភាពរបស់ខ្លួនអាចលុបចោលបាន។[49]

របៀបផ្តល់សច្ចានុមតិលើកិច្ចសន្យា ក៏ដូចគ្នាទៅនឹងរបៀបលុបចោលកិច្ចសន្យាដែរ គឺអ្នកដែលមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិទៅលើកិច្ចសន្យាបានតាមរយៈការជូនដំណឹងទៅភាគីម្ខាងទៀតនៃកិច្ចសន្យា។ ការផ្តល់សច្ចានុមតិ នឹងមានអានុភាពបាននៅពេលដែលការជូនដំណឹងបានទៅដល់ភាគីម្ខាងទៀត នៃកិច្ចសន្យាប៉ុណ្ណោះ និងមិនចាំបាច់ធ្វើតាមរយៈតុលាការទេ។[50] ហើយរបៀបនៃការជូនដំណឹង អាចធ្វើឡើងតាមរយៈលិខិត ឬផ្ញើរសារអេឡិចត្រូនិច ឬប្រាប់ដោយផ្ទាល់ ឬតាមទូរស័ព្ទ ។ល។

លើសពីនេះ ក្នុងករណីដែលអ្នកមានសិទ្ធិផ្តល់សច្ចានុមតិ បានធ្វើនូវសកម្មភាពមួយចំនួនដែលបង្ហាញថាគាត់ទទួលស្គាល់នូវកិច្ចសន្យានោះ ច្បាប់ចាត់ទុកថាជា សច្ចានុមតិដែលច្បាប់កំណត់។ សច្ចានុមតិដែលច្បាប់កំណត់មាន ០៤(បួន) ករណី ដូចខាងក្រោម៖

[48]មាត្រា ៧ កថាខណ្ឌ១ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី,លេខ នស/រកម/០៥១១/00៧, ៣១ ឧសភា ២០១១

[49]សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, កំណត់មាត្រា៣៦១

[50]មេរៀនភាគ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ៥, ឆ្នាំ២០១៦

-ការអនុវត្តកាតព្វកិច្ចទាំងមូល ឬមួយផ្នែកចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬ ការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ។

ឧទាហរណ៍៖ A បានព្រមព្រៀងទិញគំនូរពី B ដោយភាន់ច្រលំថា គំនូរនោះគូរឡើងដោយវិចិត្រករ ដ៏ល្បីល្បាយ C។ A និង B បានព្រមព្រៀងថា នឹងបង់ប្រាក់ក្នុងរយៈពេលពីរសប្តាហ៍បន្ទាប់ពីបានទទួលគំនូរនោះ។ បន្ទាប់មក A បានដឹងថាខ្លួនមានការភាន់ច្រលំទៅលើម្ចាស់ស្នាដៃគំនូរនោះ តែ A នៅតែព្រមបង់ប្រាក់ថ្លៃគូរទាំងអស់ឱ្យទៅ B។ ករណីនេះ A មិនអាចលុបចោលកិច្ចសន្យាវិញបានទេ ព្រោះខ្លួនបានអនុវត្តកាតព្វកិច្ចរួចហើយ ទោះបីជាដឹងថាមានការឆបោកក៏ដោយ ព្រោះច្បាប់កំណត់ថាជាការផ្តល់សច្ចានុមតិ។

-ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬការទាមទារឲ្យភាគីម្ខាងទៀតអនុវត្ត។

ឧទាហរណ៍៖ A និង B បានបង្កើតកិច្ចសន្យាទិញលក់ ទូរទស្សន៍មួយគ្រឿង ដោយ B បានប្រាប់ថាទូរទស្សន៍នេះជាផលិតផលមកពីប្រទេសអាមេរិក។ ភាគីទាំងពីរព្រមព្រៀងគ្នាឲ្យ B ដឹកជញ្ជូនទូរទស្សន៍នោះទៅផ្ទះរបស់ A។ មុនពេល B ដឹងជញ្ជូនទូរទស្សន៍នោះ មកឲ្យ A ភាគី A បានដឹងថាទូរទស្សន៍នោះមិនមែនជាផលិតផលរបស់ប្រទេសអាមេរិកទេ តែ A នៅតែទាមទារឱ្យ B ដឹងទូរទស្សន៍នោះមកតាមការព្រមព្រៀង។ ករណីនេះ ក៏ជាការផ្តល់សច្ចានុមតិតាមច្បាប់កំណត់ដែរ ដូច្នេះ A មិនអាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យាវិញបានទេ។

-អនុប្បទាន ឬ ការចាត់ចែងផ្សេងទៀត នូវសិទ្ធិទាំងមូលឬមួយផ្នែកចំពោះសិទ្ធិ ដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន។

ឧទាហរណ៍៖ A និង B បានព្រមព្រៀងគ្នាទិញលក់ឆ្នាំងអ៊ុតបុរាណមួយក្នុងតម្លៃ ២០០,០០០ ដុល្លារអាមេរិក ដោយ B បានប្រាប់ថា ឆ្នាំងអ៊ុតបុរាណនោះមានអាយុកាល ២,០០០ ឆ្នាំមកហើយ តែការពិត ឆ្នាំងអ៊ុតនោះមានអាយុកាលត្រឹមតែ ១,០០០ ឆ្នាំតែប៉ុណ្ណោះ។ ក្រោយមក A បានដឹងពីការពិត តែមិនបានអនុវត្តសិទ្ធិលុបចោលកិច្ចសន្យានោះវិញទេ ហើយបានធ្វើការលក់ឆ្នាំងអ៊ុតបុរាណនោះឲ្យទៅតតិយជនម្នាក់ទៀត។ ដោយសារ A បានចាត់ចែងឆ្នាំងអ៊ុតនោះទាំងដែលបានដឹងថាខ្លួនអាចលុបចោលកិច្ចសន្យាបាន គឺជាការផ្តល់សច្ចានុមតិដែលកំណត់ដោយច្បាប់ ហេតុដូច្នេះ A មិនអាចអនុវត្តិសិទ្ធិលុបចោលបានទៀតទេ។

ទោះបីជាយ៉ាងណាក៏ដោយ សច្ចានុមតិដែលកំណត់ដោយច្បាប់ នឹងមិនកើតឡើងឡើយ ប្រសិនបើអ្នកបង្ហាញឆន្ទៈ មានឋបនីយថា ខ្លួនមិនបានផ្តល់សច្ចានុមតិ នៅពេលដែលហេតុដែលបានកំណត់នៅក្នុងករណីទាំងបីខាងលើនេះកើតឡើង។[51] ពាក្យថា "ឋបនីយថាខ្លួនមិនបានផ្តល់សច្ចានុមតិ" មានន័យថា

[51]មាត្រា៣៦២ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បុគ្គលដែលបានធ្វើសកម្មភាពត្រូវបង្ហាញចេញមកក្រៅថាខ្លួនមិនបានផ្ដល់សច្ចានុមតិទេ ទោះតាមការសរសេរ ឬតាមការនិយាយក្ដី។[52]

ឧទាហរណ៍៖ A ជាអនីតិជន បានបង្កើតកិច្ចសន្យាទិញលក់ដីចម្ការទុរេនមួយកន្លែង។ B ដែលជាអ្នកមានអំណាចមេបាបានប្រគល់ប្រាក់ថ្លៃទិញលក់នោះឱ្យទៅម្ចាស់ចម្ការ ដោយសារដីនោះនឹងត្រូវរឹបអូសដោយម្ចាស់បំណុល បើម្ចាស់ចម្ការមិនព្រមសងបំណុល។ ពេលប្រគល់ប្រាក់នោះ B បានបញ្ជាក់ជាមួយម្ចាស់ចង្ការថា នេះមិនមែនជាការផ្ដល់សច្ចានុមតិលើសកម្មភាពទិញលក់របស់ A ទេ។ ដូច្នេះ វាមិនមែនជាសច្ចានុមតិដែលច្បាប់កំណត់ទេ។

## ២.៣.អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោលកិច្ចសន្យា

អាជ្ញាយុកាល គឺជាអំឡុងពេលមួយដែលកំណត់ដោយច្បាប់។ ការកន្លងហួសនៃអំឡុងពេលនេះ បង្កើតឲ្យមានអានុភាពនៃលទ្ធកម្ម ឬការរលត់សិទ្ធិណាមួយ។[53] ដូចនេះ អាជ្ញាយុកាលនៃការរលត់សិទ្ធិលុបចោល មានន័យថា ជាអំឡុងពេលមួយដែលសិទ្ធិលុបចោលកិច្ចសន្យារបស់អ្នកមានសិទ្ធិលុបចោលត្រូវរលត់ដោយសារហួសអំឡុងពេលដែលច្បាប់បានកំណត់។ ការទទួលស្គាល់សិទ្ធិក្នុងការលុបចោលកិច្ចសន្យា ទោះបីមូលហេតុវិការៈនៃការបង្ហាញឆន្ទៈក្ដី ដោយមូលហេតុអសមត្ថភាពក្ដី គឺក្នុងគោលដៅការពារផលប្រយោជន៍របស់អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ និងជនត្រូវបានកម្រិតសមត្ថភាពផងដែរនោះ ផលប្រយោជន៍របស់ភាគីម្ខាងទៀត ក៏ត្រូវបានយកមកពិចារណាផងដែរ។ យើងឃើញថា ច្បាប់កំណត់អំពីអំឡុងពេលដែលអ្នកមានសិទ្ធិលុបចោលនៅមានសិទ្ធិក្នុងការលុបចោលកិច្ចសន្យា ក៏ដូចជាសិទ្ធិក្នុងការទាមទារឲ្យសងតាមបញ្ញត្តិស្ដីពីចម្រើនដោយហេតុបែបនេះ គឺដោយសារផលប៉ះពាល់ដោយមូលហេតុនៃការលុបចោលកិច្ចសន្យា គឺត្រឹមលក្ខណៈឯកជនប៉ុណ្ណោះ ហើយហេតុទាំងអស់នោះអាចកើតឡើងជារឿយៗក្នុងពាណិជ្ជកម្ម និងក្នុងជីវិតរស់នៅប្រចាំថ្ងៃ ដូចនេះបើច្បាប់មិនកំណត់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុចចោលនោះទេ ពិតជាមានភាពមិនស្រួលចិត្តក្នុងការបង្កើតកិច្ចសន្យា រួមទាំងក្រោយពេលបង្កើតកិច្ចសន្យាផងដែរ តួយ៉ាងប្រសិនបើយើងទទួលស្គាល់សិទ្ធិលុបចោលរបស់អ្នកលុបចោលដោយគ្មានកំណត់ពេល នោះនឹងនាំឲ្យមានអស្ថេរភាពផ្នែកកិច្ចការជំនួញរបស់ភាគីម្ខាងទៀតនៃការលុបចោលជាមិនខាន ដោយហេតុថាមិនដឹងថាជាកិច្ចសន្យាអាចនឹងត្រូវបានលុបចោលនៅពេលណានោះទេ។ អាស្រ័យហេតុនេះ ដើម្បីធានានូវតុល្យភាពរវាងភាគីទាំងសងខាងនៃកិច្ចសន្យា ទើបច្បាប់បានកំណត់នូវរយៈពេលច្បាស់លាស់សម្រាប់អ្នកមានសិទ្ធិលុបចោលក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន។

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល ត្រូវបានបែងចែកចេញជាពីរករណីដូចខាងក្រោម៖

[52]មេរៀនភាគ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ១៥, ឆ្នាំ២០១៦

[53]សន្ទានុក្រមផ្នែករដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចំណុចទី១៩៦

**ករណីទី១៖** ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុងរយៈពេលបីឆ្នាំ គិតចាប់តាំងពីពេលដែលខ្លួនក្លាយជាអ្នកដែលអាចផ្តល់សច្ចានុមតិ នោះសិទ្ធិលុបចោល និងសិទ្ធិទាមទារឲ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើងដោយសារការលុបចោលនោះត្រូវរលត់។[54]

រយៈពេលដែលអាចផ្តល់សច្ចានុមតិបាន មានលក្ខណៈខុសគ្នារវាងអ្នកបង្ហាញឆន្ទៈដោយមានវិការៈ និងអសមត្ថជន។ ចំពោះអ្នកបង្ហាញឆន្ទៈដោយមានវិការៈ អាចសម្រេចចិត្តអំពីការផ្តល់សច្ចានុមតិចាប់តាំងពីពេលដែលបានដឹងអំពីវិការៈនៃការបង្ហាញឆន្ទៈ ហើយអាជ្ញាយុកាលចាប់ផ្តើមរាប់ពីពេលនោះឯង។ ចំណែកឯករណីអសមត្ថជន ពួកគេអាចធ្វើការផ្តល់សច្ចានុមតិ នៅពេលដែលពួកគេក្លាយជាជនមានសមត្ថភាព ហើយអាជ្ញាយុកាលចាប់ផ្តើមគណនាពីពេលនោះតទៅ។ ទន្ទឹមនឹងនេះ ចំពោះអ្នកអាណាព្យាបាលនៃជនដែលត្រូវបានកម្រិតសមត្ថភាព អាជ្ញាយុកាលត្រូវចាប់ផ្តើមរាប់ពីពេលដែលអាណាព្យាបាលបានដឹងអំពីមូលហេតុនៃការលុបចោល។

**ករណីទី២៖** ប្រសិនបើហួសអំឡុងពេល១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាពនោះ សិទ្ធិលុបចោលក៏ត្រូវរលត់ដែរ។

នៅពេលដែលអ្នកមានសិទ្ធិលុបចោលបានដឹងអំពីមូលហេតុ នៃការលុបចោលក្រោយពេល១០ឆ្នាំនៃការបង្កើតកិច្ចសន្យា នោះយើងមិនគួរទទួលសិទ្ធិលុបចោលនោះទៀតឡើយ ព្រោះថានេះជាអំឡុងពេលដ៏យូរមួយ ហើយម្យ៉ាងទៀត កម្មវត្ថុនៃកិច្ចសន្យាអាចនឹងត្រូវបានចាត់ចែងបន្តប៉ុន្មានដងរួចទៀតក៏ថាបាន ដូចនេះបើនៅតែទទួលស្គាល់នូវសិទ្ធិលុបចោលនៅរយៈពេលហួសពី១០ឆ្នាំ ចាប់តាំងពីកិច្ចសន្យាត្រូវបានបង្កើត នឹងធ្វើឲ្យមានស្ថានភាពស្មុគស្មាញមិនខាន។ ហេតុដូចនេះហើយ ទើបច្បាប់កំណត់ថា ប្រសិនបើអ្នកមានសិទ្ធិលុបចោលបានដឹងអំពីមូលហេតុនៃការលុបចោលក្នុងអំឡុងពេលហួសពី១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃកិច្ចសន្យាត្រូវបានបង្កើត នោះសិទ្ធិលុបចោលកិច្ចសន្យានឹងត្រូវរលត់។

យើងឃើញថា នៅក្នុងករណីទី១ បានកំណត់ថា សិទ្ធិលុបចោល និងសិទ្ធិទាមទារឲ្យសងសេចក្តីចម្រើនដោយឥតហេតុ ត្រូវរលត់ក្នុងកំឡុងពេល៣ឆ្នាំ គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិ ចំណែកឯក្នុងករណីទី២វិញ បានកំណត់ត្រឹមតែសិទ្ធិលុបចោលប៉ុណ្ណោះដែលត្រូវរលត់ ប្រសិនបើហួសរយៈពេល១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាព ដោយពុំមានកំណត់អំពីសិទ្ធីទាមទារឲ្យសងតាមសេចក្តីច្រើនដោយឥតហេតុទេ។ ដូចនេះ ចំពោះករណីទី២ យើងមិនអាចយកសិទ្ធិទាមទារឲ្យសងតាមសេចក្តីចម្រើនដោយឥតហេតុមកអនុវត្តទេ មានន័យថា សិទ្ធិនេះត្រូវរលត់ក្នុងអំឡុងពេល៣ឆ្នាំ (ករណីទី១)។

[54]មាត្រា៣៦៣ កថាខណ្ឌ១ វាក្យខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## ២.៤.អានុភាពនៃការលុបចោលកិច្ចសន្យា

អានុភាព គឺជាផលគតិយុត្ត ដែលកើតចេញពីលិខិតគតិយុត្ត ដូចជា កិច្ចសន្យា ច្បាប់ សេចក្តីសម្រេចរបស់តុលាការ សេចក្តីសម្រេចរបស់រដ្ឋបាល។ល។[55] យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា សកម្មភាព (កិច្ចសន្យា ឬសកម្មភាពឯកតោភាគី) ដែលអាចលុបចោលបានមានសុពលរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ។[56] ត្រង់ចំណុចនេះ មានន័យថា កិច្ចសន្យានោះមានមូលហេតុនៃការលុបចោល ដែលអាចជាការបង្ហាញឆន្ទៈដោយមានវិការៈ ឬមូលហេតុនៃការកង្វះសមត្ថភាពរបស់ភាគី ប៉ុន្តែពុំទាន់ត្រូវបានលុបចោល ដូចនេះកិច្ចសន្យានោះមានអានុភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលកិច្ចសន្យានោះ ដែលយើងអាចហៅថា សុពលភាពមិនពេញលេញ។ ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោលបានផ្តល់សច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវមានសុពលភាពជាស្ថាពរ។[57] ប្រសិនបើអ្នកមានសិទ្ធិលុបចោល ឬអ្នកដែលមានសិទ្ធិផ្តល់សច្ចានុមតិបានផ្តល់សច្ចានុមតិស្របតាមលក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ ចំពោះកិច្ចសន្យាដែលមានមូលហេតុនៃការលុបចោល នោះបានសេចក្តីថា សុពលភាពមិនពេញលេញបានក្លាយទៅជាសុពលភាពស្ថាពរ។ ផ្ទុយទៅវិញ ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោល សកម្មភាពនេះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង[58] ឬអាចនិយាយម្យ៉ាងទៀតថា ការលុបចោលកិច្ចសន្យាធ្វើឲ្យមានអានុភាពប្រតិសកម្ម។ អានុភាពប្រតិសកម្ម គឺជាអានុភាពនៃលក្ខខណ្ឌគតិយុត្ត ដែលមានទៅលើសកម្មភាពពីអតីតកាល ឬអាចហៅថាអានុភាពធាក់ថយក្រោយដែលអាចនាំឲ្យមានការប្រតិបត្តិ នូវស្ថានភាពដើមតាំងពីពេលចាប់ផ្តើមបង្កើតកិច្ចសន្យានោះត្រឡប់មកវិញ។ ប្រសិនបើអ្នកមានសិទ្ធិលុបចោលបានសម្រេចចិត្តលុបចោលកិច្ចសន្យាដែលមានមូលហេតុនៃការលុបចោល អាចសន្មតបានថា អ្នកមានសិទ្ធិលុបចោលមិនចង់ឲ្យកិច្ចសន្យានោះមានអានុភាពមកលើខ្លួនតាំងពីដំបូងមកម្ល៉េះ។ សរុបមកអានុភាពនៃការលុបចោលកិច្ចសន្យា គឺធ្វើឲ្យកិច្ចសន្យានោះបាត់បង់អានុភាព និងមានន័យស្មើនឹងគ្មានការបង្កើតកិច្ចសន្យាតាំងពីដំបូងម្ល៉េះ។

បន្ទាប់ពីសិក្សាអំពីការលុបចោលកិច្ចសន្យារួចមក យើងឃើញថា មូលហេតុនៃការលុបចោលកិច្ចសន្យាចែកជា ២ធំៗគឺ វិការៈនៃការបង្ហាញឆន្ទៈ និងកង្វះសកម្មភាពរបស់ភាគី។ ច្បាប់ក៏បានកំណត់អំពីអ្នកមានសិទ្ធិលុបចោល វិធីនៃការលុបចោល/ការផ្តល់សច្ចានុមតិ និងអាជ្ញាយុកាលនៃការរលត់សិទ្ធិលុបចោល។ ទោះបី

[55] សន្ទានុក្រមផ្នែករដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចំណុច១៧២

[56] មាត្រា៣៥៨ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[57] មាត្រា៣៥៨ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[58] មាត្រា៣៥៨ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

កិច្ចសន្យាមានមូលហេតុនៃការលុបចោលក៏ដោយ ប្រសិនបើអ្នកមានសិទ្ធិលុបចោល មិនបានប្រកាសលុបចោលកិច្ចសន្យា នោះកិច្ចសន្យាមានសុពលភាព។ ម្យ៉ាងវិញទៀត ប្រសិនបើហួសអាជ្ញាយុកាលនៃការប្រកាសលុបចោលកិច្ចសន្យា បានន័យថា សិទ្ធិលុបចោលត្រូវបានរលត់ អ្នកមានសិទ្ធិលុបចោល មិនអាចធ្វើការអះអាងអំពីការលុបចោលកិច្ចសន្យាបានទេ នោះកិច្ចសន្យាក្លាយជាកិច្ចសន្យាសុពល។ ផ្ទុយទៅវិញ ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានប្រកាសលុបចោលកិច្ចសន្យា ក្នុងអំឡុងពេលដែលច្បាប់ផ្ដល់សិទ្ធិលុបចោល នោះនឹងធ្វើឲ្យកិច្ចសន្យានោះបាត់បង់អានុភាព និងចាត់ទុកជាមោឃៈតាំងពីដំបូង។ ដោយសារតែផលប៉ះពាល់នៃកិច្ចសន្យាដែលមានមូលហេតុនៃការលុបចោល គឺចំពោះតែភាគី ដូចនេះច្បាប់ផ្ដល់លទ្ធភាពដល់អ្នកមានសិទ្ធិលុបចោលជាអ្នកសម្រេចថាលុប ឬមិនលុប (ផ្ដល់សច្ចានុមតិ)។ ការលុបចោល ឬសច្ចានុមតិ ត្រូវធ្វើឡើងដោយការជូនដំណឹងទៅភាគីម្ខាងទៀត ហើយមានអានុភាព នៅពេលដែលដំណឹងនោះបានដល់ភាគីម្ខាងទៀត។ ដូចនេះការយល់ដឹងអំពីចំណុចសំខាន់ៗដែលពាក់ព័ន្ធនឹងការលុបចោលសន្យា ពិតជាសំខាន់ណាស់ ព្រោះក្នុងការបង្កើតកិច្ចសន្យា ភាគីតែងមានក្ដីសង្ឃឹមចំពោះកិច្ចសន្យា និងចង់ឲ្យកិច្ចសន្យានោះមានសុពលភាព ដែលតម្រូវឲ្យភាគីជៀសវាងនូវមូលហេតុដែលនាំឲ្យមានការលុបចោល។

# សេចក្ដីសន្និដ្ឋាន

ផ្អែកទៅតាមរយៈការសសិក្សាស្រាវជ្រាវ ព្រមទាំងការបកស្រាយយ៉ាងក្បោះក្បាយខាងលើមកនេះ ទាក់ទងទៅនឹងប្រធានបទ ការលុបចោលកិច្ចសន្យា វាពិតជាមានសារៈសំខាន់ក្នុងការដែលភាគីនៃកិច្ចសន្យាចង់បដិសេធការអនុវត្តកិច្ចសន្យាដោយសារកិច្ចសន្យា ដែលបង្កើឡើងដោយមានមូលហេតុនៃការលុបចោល។ នៅក្នុងសង្គមបច្ចុប្បន្នការបង្កើតកិច្ចសន្យាគឺកើតមានជារៀងរាល់ថ្ងៃ ទន្ទឹមនឹងនោះដែរការបង្កើតកិច្ចសន្យាទាំងអស់នេះមាន កិច្ចសន្យាខ្លះគឺបង្កើតឡើងដោយ ជនដែលខ្វះសមត្ថភាពខាងឆន្ទៈ ជនដែលខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព ដូច្នេះហើយទើបក្រមរដ្ឋប្បវេណីបញ្ញត្តិថា កិច្ចសន្យាដែលបង្កើតឡើងដោយជនទាំងនេះអាចលុបចោលបាន ដើម្បីការពារនូវផលប្រយោជន៍របស់ពួកគេ ព្រោះដោយសារតែគម្លាតខុសគ្នា និងឆន្ទៈនៃការគិតពិចារណាពួកគេទាំងនោះនៅមានកម្រិត។ ម្យ៉ាងទៀតកិច្ចសន្យាដែលកើតចេញពីការបង្ហាញឆន្ទៈមិនពិតរបស់ភាគីនៃកិច្ចសន្យាមានដូចជា ការភាន់ច្រឡំ ការឆបោក ពត៌មានមិនពិត ការរំលោភលើស្ថានភាព អំពើកេងចំណេញហួសហេតុ ការគម្រាមកំហែង ក៏ជាមូលហេតុនៃការលុបចោលផងដែរ ព្រោះកិច្ចសន្យានេះមិនបានកើតចេញពីឆន្ទៈផ្ទាល់របស់ភាគីនៃកិច្ចសន្យា ហើយបើទទួលស្គាល់នូវកិច្ចសន្យាបែបនេះ ហាក់ដូចជាគាំទ្រនូវការបង្កើតកិច្ចសន្យាដែលមិនស្របទៅតាមឆន្ទៈរបស់ភាគីនៃកិច្ចសន្យា ព្រមទាំងបង្កើតឲ្យគ្មានសមភាពនៃការធ្វើជំនួញ បាត់ទាំងធ្លាក់ចុះ និងបាត់បង់នូវតម្លៃសីលធម៌ក្នុងសង្គមផងដែរ។

ទោះបីជាក្រមរដ្ឋប្បវេណី អនុញ្ញាតឲ្យកិច្ចសន្យាដែលមានមូលហេតុនៃការលុបចោលអាចលុបចោលបានប្រាកដមែន ប៉ុន្តែដោយសារតែការលុបចោលកិច្ចសន្យានេះធ្វើឲ្យប៉ះពាល់ផងដែរដល់ផលប្រយោជន៍ភាគីម្ខាងទៀត ទើបក្រមរដ្ឋប្បវេណីបានកំណត់យ៉ាងច្បាស់លាស់ពីអ្នកមានសិទ្ធិលុបចោលកិច្ចសន្យា ដែលខុសគ្នាពីមោឃភាព ព្រោះមោឃភាពគឺជាការប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ទំនៀមទំលាប់សង្គម ហើយជនណាក៏អាចអះអាងអំពីមោឃភាពបានដែរ។ បន្ថែមពីលើនេះដែរ កិច្ចសន្យាដែលមានមូលហេតុនៃការលុបចោល អ្នកដែលមានសិទ្ធិលុបចោល គឺអាចផ្ដល់សច្ចានុមតិនៃកិច្ចសន្យានោះបាន ពោលគឺទទួលស្គាល់អានុភាពជាស្ថានពរនៃកិច្ចសន្យានោះ ព្រោះអាចផ្ដល់សច្ចានុមតិនៃកិច្ចសន្យានោះបាន ពោលគឺទទួលស្គាល់អានុភាពជាស្ថាពរនៃកិច្ចសន្យានោះ ព្រោះកិច្ចសន្យាដែលមានមូលហេតុនៃការលុបចោល ក៏ជាកិច្ចសន្យាមួយដែលមានសុពលភាពដែរ ដរាបណាអ្នកដែលមានសិទ្ធិលុបចោលមិនលុបចោលកិច្ចសន្យានោះ។ ការដែលទទួលស្គាល់សុពលភាពកិច្ចសន្យាបែបនេះ គឺដោយសារតែការគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ដោយរដ្ឋមិនធ្វើការជ្រៀតជ្រែកទៅក្នុងទំនាក់ទំនងឯកជន។ មិនត្រឹមតែប៉ុណ្ណោះទេ ដើម្បីធានាឲ្យបាននូវសមភាព និងនិរ្ពនភាពដោយមិនធ្វើការការពារតែម្ខាងទៅលើតែអ្នកដែលមានសិទ្ធិលុបចោលកិច្ចសន្យា ឬ ផ្ដល់សច្ចានុមតិ ភា

គីម្ខាងទៀតនៃកិច្ចសន្យាគឺអាចជាស់តឿ ភាគីដែលមានសិទ្ធិលុបចោលឲ្យផ្តល់ ឬ មិនផ្តល់សច្ចានុមតិ ហើយក៏មានការកំណត់អាជ្ញាយុកាលសម្រាប់ការរំលត់សិទ្ធិលុបចោលផងដែរ។ ការកំណត់នូវអាជ្ញាយុកាលសម្រាប់ការរលត់សិទ្ធិលុបចោលនេះ គឺដើម្បីភាគីដែលមានសិទ្ធិលុបចោលអនុវត្តសិទ្ធិលុបចោលរបស់ខ្លួនឲ្យបានកាន់តែឆាប់រហ័សជៀសវាងអូសបន្លាយដែលនាំឲ្យមានការខាតបង់ផលប្រយោជន៍របស់ភាគីម្ខាងទៀតនៃកិច្ចសន្យា។ ការលុបចោលកិច្ចសន្យា ឬផ្តល់សច្ចានុមតិមានលក្ខណៈងាយស្រួលដោយគ្រាន់តែភាគីដែលមានចង់លុបចោលកិច្ចសន្យា ជូនដំណឹងទៅភាគីម្ខាងទៀត ដើម្បីឲ្យគាត់បានដឹងពីការលុបចោលកិច្ចសន្យានេះ ហើយនៅពេលដែលកិច្ចសន្យាត្រូវបានលុបចោល នោះកិច្ចសន្យានឹងមានអានុភាពប្រតិសកម្ម មានន័យថាកិច្ចសន្យានោះត្រូវបានចាត់ទុកជាមោឃៈ ឬ គ្មានសុពលភាពតាំងពីដំបូងមកម៉្លេះ ហើយភាគីនៃកិច្ចសន្យាមានករណីកិច្ចត្រូវសងតាវកាលិកទៅវិញទៅមកតាមបញ្ញត្តិនៃសេចក្តីចម្រើនឥតហេតុ។ អ្វីដែលបង្កឲ្យមានភាពស្មុកស្មាញគឺនៅពេលដែលតាវកាលិកត្រូវបានផ្ទេរពីភាគីដែលមានករណីកិច្ចសងតាវកាលិកទៅតតិយជន អានុភាពនៃការលុបចោលកិច្ចសន្យា ក៏កើតឡើងចំពោះតតិយជនផងដែរ។

ជាមួយនឹងការរៀបរាប់បញ្ហាខាងលើនេះ ធ្វើឲ្យយើងបានដឹងថា ការលុបចោលកិច្ចសន្យាគឺជាការបច្ចេកទេសមួយដែលប្រើសម្រាប់បដិសេធការអនុវត្តកិច្ចសន្យា ប៉ុន្តែដោយសារតែប្រជាពលរដ្ឋយើងមិនទាន់មានចំណេះដឹងទូលំទូលាយ ក៏ដូចជាការយល់ដឹងពាក់ព័ន្ធទៅនឹងការលុបចោលកិច្ចសន្យា ធ្វើឲ្យពួកគាត់បានបាត់បង់នូវផលប្រយោជន៍ជាច្រើនតាមរយៈការបង្កើតកិច្ចសន្យា ដែលធ្វើឲ្យខាតបង់ដល់មុខជំនួញរបស់គាត់។ នេះសបញ្ជាក់ឲ្យបានដឹងថាប្រជាពលរដ្ឋមានចំណេះដឹងតិចតួចណាស់ ជាពិសេសខាងផ្នែកច្បាប់ ដោយពួកគាត់ភាគច្រើនអនុវត្តតែវិធានទំនៀមទំលាប់ តាមការយល់ឃើញដោយមិនមានមូលដ្ឋានច្បាស់លាស់សម្រាប់ការប្រកបកិច្ចការជំនួញមួយប្រកបដោយសមភាពនោះទេ។

ជារួមដោយសារតែប្រទេសកម្ពុជា ជាប្រទេសមួយដែលកំពុងតែអភិវឌ្ឍន៍ ហើយម្យ៉ាងទៀតដោយសារតែការយល់ដឹងរបស់ប្រជាពលរដ្ឋយើងនៅមានកម្រិត ធ្វើឲ្យការអនុវត្តច្បាប់នានាស្ថិតនៅក្នុងកម្រិតទាបមួយនៅឡើយ ដែលបង្កជាបញ្ហាប្រឈម ជាពិសេសគឺនីតិឯកជនដែលគ្រប់គ្រងជីវភាពរបស់បុគ្គលឯកជនក្នុងជីវភាពប្រចាំថ្ងៃ។ ខ្ញុំបាទសង្ឃឹមថាសារណាមួយនេះនឹងក្លាយទៅជាឯកសារមួយដ៏មានតម្លៃ ក្នុងការសិក្សាស្រាវជ្រាវដល់អ្នកសិក្សាស្រាវជ្រាវលើប្រធានបទនេះ ជាពិសេសគឺក្នុងការចែករំលែកចំណេះដឹងរបស់ខ្ញុំបាទដែលមានទៅកាន់សាធារណជន។

## អនុសាសន៍

ដើម្បីជាការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងក្នុងប្រធានបទខាងលើ ខ្ញុំបាទសំណូមពរដល់ស្ថាប័នរដ្ឋ ស្ថាប័នឯកជន រួមតាំងបុគ្គលដែលពាក់ព័ន្ធដូចខាងក្រោម៖

១.រដ្ឋាភិបាល៖ ពង្រឹងនូវការផ្សព្វផ្សាយ អប់រំពីច្បាប់នានាឲ្យបានទូលំទូលាយតាមរយៈការដាក់បញ្ចូលក្នុងប្រព័ន្ធសម្រាប់សិស្សានុសិស្ស ផ្សព្វផ្សាយតាមរយៈប្រព័ន្ធអេឡិចត្រូនិច ទូរទស្សន៍ វិទ្យុ ទស្សនាវដ្ដី កាសែតសម្រាប់ប្រជាពលរដ្ឋទូទៅ ជាពិសេសបង្កើតនូវសិក្ខាសាលាសម្រាប់ផ្សព្វផ្សាយផ្ទាល់ដល់ប្រជាពលរដ្ឋ ដែលនៅតំបន់ដាច់ស្រយាលដែលមិនមានលទ្ធភាពអាចយល់ដឹងពីច្បាប់។

២.ក្រសួងយុត្តិធម៌៖ គប្បីចេញនីតិវិធីឲ្យមន្ត្រីដែលជាអ្នកអនុវត្តច្បាប់ យកចិត្តទុកដាក់ពន្លឿនក្នុងការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ តាមរយៈការផ្ដល់មតិយោបល់ដល់ពួកគាត់ ឬ ផ្ដល់មធ្យោបាយផ្សេងៗដើម្បីឲ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្បាស់ពីច្បាប់ ជាចំណែកក្នុងការចូលរួមអនុវត្តច្បាប់ផងដែរ។

៣.ស្ថាប័នតុលាការ៖ ពន្លឿននីតិវិធីនៃការដោះស្រាយវិវាទតាមផ្លូវតុលាការឲ្យបានលឿន និងមានប្រសិទ្ធិភាព ដើម្បីបុគ្គលដែលមានវិវាទអាចដោះស្រាយវិវាទរបស់ពួកគាត់បានកាន់តែឆាប់រហ័ស ព្រោះកាលណាតែនីតិវិធីតាមផ្លូវតុលាការមានរយៈពេលយូរធ្វើឲ្យពួកគាត់ចំណាយពេលវេលាបាត់បង់ផលប្រយោជន៍ក្នុងការប្រកបចិញ្ចឹមជីវិត ដែលជាហេតុធ្វើឲ្យពួកគាត់មិនចង់សោះស្រាយវិវាទតាមប្រព័ន្ធតុលាការ។

៤.សិស្ស និស្សិត៖ គប្បីខិតខំប្រឹងប្រែងរៀនសូត្រ ស្រូបយកចំណេះវិជ្ជាផ្សេងៗ ព្រោះពួកគាត់សុទ្ធសឹងតែជនជានមនុស្ស ដែលសង្គមត្រូវការជាចាំបាច់ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិឲ្យរីកចម្រើន នាពេលអនាគត ជាពិសេសគួរមានការយល់ដឹងច្រើនអំពីច្បាប់ ទោះបីជាពួកគាត់ខ្លះមិនបានសិក្សាមហាវិទ្យាល័យនីតិសាស្ត្រពិតមែន ព្រោះដើម្បីកសាងប្រទេសជាតិឲ្យក្លាយជាប្រទេសនីតិរដ្ឋដ៏ពិតប្រាកដ។ ដូចនេះ សិស្ស និស្សិតគួរតែធ្វើជាគំរូក្នុងការគោរពច្បាប់ វៀងចាកការប្រព្រឹត្តបទល្មើស ជាជាងនេះទៅទៀតគឺត្រូវចែករំលែកពត៌មាន ក៏ដូចជាចំណេះដឹងទៅកាន់ក្រុមគ្រួសាររបស់ខ្លួន រួមទាំងអ្នកដទៃទៀត។

៥.ប្រជាពលរដ្ឋ គប្បីចូលរួមក្នុងការលើកស្ទួយ និងអនុវត្តច្បាប់ដើម្បីឲ្យច្បាប់កាន់តែមានប្រសិទ្ធិភាពជាពិសេសការប្រើប្រាស់ច្បាប់ជាគោលក្នុងជីវិភាពរស់នៅប្រចាំថ្ងៃ ដូចជាការធ្វើជំនួញ អាជីវកម្ម ឬរបររកស៊ីចិញ្ចឹមជីវិតផ្សេងទៀត ព្រោះកាលណាអនុលោមច្បាប់ មិនសូវមានហានិភ័យក្នុងការបាត់បង់ផលប្រយោជន៍ ឬការក្លែងបន្លំពីជនទុច្ចរិត ហើយច្បាប់អាចការពារផលប្រយោជន៍របស់ពួកគាត់បានយ៉ាងពេញលេញ។ ជាមួយគ្នានេះដែរ ប្រជាពលរដ្ឋគួរស្វែងរកពត៌មានពីច្បាប់នានា ដើម្បីឲ្យកាន់តែយល់ច្បាស់ពីច្បាប់ ព្រោះច្បាប់ជាធាតុសំខាន់ក្នុងការរស់នៅក្នុងសង្គមបច្ចុប្បន្ន។

# ឯកសារយោង

១.សៀវភៅក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ របស់ក្រសួងយុត្តិធម៌, វិច្ឆិកា ២០១៦។

២.ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

៣.សៀវភៅច្បាប់កិច្ចសន្យា មេធាវី ជ្រា ឈុនឡេង, ២០១៨។

៤.សៀវភៅកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២, ១០ មេសា ២០១០។

៥.សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១, រៀបរៀងដោយក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជជីវៈតុលាការ បោះពុម្ពលើកទី១, ភ្នំពេញ មេសា ២០១៣។

៦.សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១, ០៩ ធ្នូ ២០០៩។

៧.មេរៀនទី២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, រៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ, បោះពុម្ពលើកទី១, ភ្នំពេញ វិច្ឆិកា ២០១៦។

៨.សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី,លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។

៩.សន្ទានុក្រមផ្នែករដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀងលុបចោលកិច្ចសន្យា**
**ស្តីពីការផ្តល់សិទ្ធិផ្តាច់មុខកាន់កាប់គម្រោងដីពុះឡូតិ៍**
**ស្ថិតនៅភូមិបឹងខ្នារ ភូមិខ្នារ ឃុំព្រែជ ស្រុកអង្គស្នួល ខេត្តកណ្តាល**
ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៨ រវាងលោកស្រី **និត ពៅ** និងលោកស្រី **ខណ្ណា សុភាពមុន្នី**
ជាភាគី "**ក**" និងលោក **មៀច សំរួល** និងលោក **សុខ ហាច** ជាភាគី "**ខ**"

កិច្ចព្រមព្រៀងនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៨ រវាងនិងដោយ៖

អ្នកស្រី **និត ពៅ** កើតថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ១៩៦៦ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៨៥៣៨៩៥ អាសយដ្ឋានផ្ទះលេខ ៥៥៦ ផ្លូវ២១K៣ ភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ និងអ្នកស្រី **ខណ្ណា សុភាពមុន្នី** កើតថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៧១ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៣២២២១៥ អាសយដ្ឋានផ្ទះលេខ ១០៥ ផ្លូវ៩៣ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ពីពេលនេះតទៅហៅថាភាគី "**ក**" និង

លោក **មៀច សំរួល** កើតថ្ងៃទី ៩ ខែឧសភា ឆ្នាំ១៩៨០ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០១៦១៨២២១២ អាសយដ្ឋានផ្ទះគ្មានលេខ ផ្លូវជាតិលេខ ៥ ភូមិកំពង់លើ ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិសាត់ និងលោក **សុខ ហាច** កើតថ្ងៃទី ៥ ខែធ្នូ ឆ្នាំ១៩៨១ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០៩០០៥៣៩៩ អាសយដ្ឋានផ្ទះលេខ F ២០ ភូមិឈើនាត ឃុំបន្ទាយអំពិល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ពីពេលនេះតទៅហៅថាភាគី "**ខ**" ។

**មុខ្ញកថា៖**

ដោយយោងលើកិច្ចសន្យាស្តីពីការផ្តល់សិទ្ធិផ្តាច់មុខកាន់កាប់គម្រោងដីពុះឡូតិ៍ ស្ថិតនៅភូមិបឹងខ្នារ ភូមិខ្នារ ឃុំព្រែជ ស្រុកអង្គស្នួល ខេត្តកណ្តាល ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៨។

ដោយហេតុថា ភាគី "**ក**" និងភាគី "**ខ**" បានឯកភាពគ្នាទាំងស្រុងលុបចោលកិច្ចសន្យា ស្តីពី ការផ្តល់សិទ្ធិផ្តាច់មុខកាន់កាប់គម្រោងដីពុះឡូតិ៍ ស្ថិតនៅភូមិបឹងខ្នារ ភូមិខ្នារ ឃុំព្រែជ ស្រុកអង្គស្នួល ខេត្តកណ្តាល ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៨ ដែលបានធ្វើកន្លងមក។

ដោយហេតុថាភាគី "**ខ**" មានគ្នាពីរនាក់ និងមានការសន្យាផ្ទៃក្នុងក្នុងការបែងចែកផលប្រយោជន៍ពីការលក់គម្រោងដីឡូតិ៍ខាងលើ ចង់បានការធានាច្បាស់លាស់លើផលប្រយោជន៍ដែលម្នាក់ៗត្រូវទទួល និងចង់ឱ្យមានការសម្របសម្រួលពីភាគី"**ក**" ។

ដោយហេតុថា ភាគី "**ក**" ត្រូវការភាគី "**ខ**" ធ្វើការបិទបញ្ជី និងរាយការណ៍ ធ្វើតារាងបង់ប្រាក់របស់អតិថិជន និងបញ្ជីដីឡូតិ៍លក់រួច និងឡូតិ៍ដែលមិនទាន់លក់។

ដោយហេតុថាភាគី "**ខ**" បានឯកភាពគ្នាបែងចែកផលប្រយោជន៍ផ្ទៃក្នុងរួចហើយ។

ភាគី "**ក**" និងភាគី "**ខ**" បានឯកភាពចុះកិច្ចព្រមព្រៀងនេះដើម្បីរំលាយ/លុបចោលកិច្ចសន្យាដូចបានយោងខាងលើ ដោយគោរពតាមលក្ខខណ្ឌរាល់ប្រការដូចខាងក្រោម ៖

**ប្រការ ១.,**

ភាគី "**ក**" និងភាគី "**ខ**" បានយល់ព្រមរំលាយ/លុបចោលកិច្ចសន្យាកិច្ចសន្យាស្តីពីការផ្តល់សិទ្ធិផ្តាច់មុខកាន់កាប់គម្រោងដីពុះឡូតិ៍ ស្ថិតនៅភូមិបឹងខ្នារ ភូមិខ្នារ ឃុំព្រែជ ស្រុកអង្គស្នួល ខេត្តកណ្តាល ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៨ ចោលទាំងស្រុងចាប់ពីថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៨ នេះតទៅ។

**ប្រការ ២.,**

ភាគី "**ខ**" បានយល់ព្រមធ្វើបញ្ជីឈ្មោះអតិថិជន និងចំនួនដីឡូតិ៍នៅសល់ពីការលក់ជូនអតិថិជន ឱ្យ ភាគី "**ក**" ព្រមទាំងទូទាត់ប្រាក់ថ្លៃលក់ក្នុងគំរោងជូនមក ភាគី "**ក**" ។

**ប្រការ ៣.,**

ក្រោយពីរំលាយកិច្ចសន្យានេះហើយ ភាគី "**ខ**" និងបន្តដោះស្រាយផ្ទៃក្នុងខ្លួនធ្វើយ៉ាងណាដើម្បីធានារក្សាផលប្រយោជន៍របស់ ភាគី "**ក**" ។

ដោយសារ ភាគី "**ខ**" មានគ្នា២នាក់ គឺ លោក **សុខ ហាង** និងលោក **មៀច សំរួល** នោះការរៀបចំបិទបញ្ជី និងការធ្វើបញ្ជីបង់ប្រាក់របស់អតិថិជន គឺ លោក **មៀច សំរួល** ជាអ្នកមានភារកិច្ចធ្វើជូន ភាគី "**ក**" ។ ការដែលលោក **សុខ ហាង** ប្រគល់ភារកិច្ចជូនលោក **មៀច សំរួល** ទទួលខុសត្រូវធ្វើបញ្ជីអតិថិជន និងបញ្ជីដីឡូតិ៍នេះ គឺដោយសារលោក **មៀច សំរួល** ជាអ្នកទទួលលុយផ្ទាល់ពីអតិថិជន។

**ប្រការ ៤.,**

ករណី ភាគី "**ខ**" មិនអាចដោះស្រាយបញ្ហាផ្ទៃក្នុងខ្លួនបាន ហើយបណ្ដាលឱ្យមានបណ្ដឹង និងផ្សេងៗ នោះ ភាគី "**ខ**" សន្យាមិនធ្វើការរាំងរាំងណាមួយក្នុងការបង្កគំរោងលក់ដីឡូតិ៍របស់ ភាគី "**ក**" ជាដាច់ខាត។

ភាគី "**ខ**" ត្រូវបិទបញ្ជី និងប្រគល់អតិថិជនជូន ភាគី "**ក**" យ៉ាងយូរត្រឹមថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៨ ជាកំហិត។

ករណីដល់ពេលកំណត់ ភាគី "**ខ**" មិនអាចបំពេញកាតព្វកិច្ចនេះបាន ភាគី "**ខ**" ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

**ប្រការ ៥.,**

លោក **មៀច សំរួល** យល់ព្រមផ្ទេរដីឡូដ៍លេខ ៧A និងប្រគល់ប្រាក់ចំនួន USD ៣,០០០ (បីពាន់ដុល្លាអាមេរិក) ជូនលោក **សុខ ហាង** ដើម្បីបញ្ចប់ការទទួលខុសត្រូវត្រឹមនេះ។ ចំពោះការនេះភាគី "**ក**" ត្រូវជួយទទួលខុសត្រូវទូទាត់ជូនលោក **សុខ ហាង** ។ តែលោក **សុខ ហាង** ត្រូវចេញប្រាក់ចំនួន USD ១,៥០០ (មួយពាន់ប្រាំរយដុល្លាអាមេរិក) សងទៅភាគី "**ក**" ដើម្បីចេញថ្លៃធ្វើប្លង់ដី។

**ប្រការ ៦.,**

លោក **មៀច សំរួល** និងលោក **សុខ ហាង** និងភាគី "**ក**" និងភាគី "**ខ**" បានយល់ព្រមដោយគ្មានការបង្ខិតបង្ខំ ឬ គាបសង្កត់ពីភាគីណាមួយ ឬ បុគ្គលដទៃទៀតឡើយ ហើយយល់ព្រមចុះហត្ថលេខា/ផ្ដិតស្នាមមេដៃសម្រាប់អនុវត្តចាប់ពីពេលនេះតទៅ។

**ស្នាមមេដៃស្ដាំ**

ភាគី "**ក**" ភាគី "**ខ**"

**បានឃើញនិងបញ្ជាក់ថា**

គូភាគីពិតជាបានយល់ព្រមផ្ដិតស្នាមមេដៃនៅចំពោះមុខមេធាវីប្រាកដមែន។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៨

**ហត្ថលេខានិងត្រាមេធាវី**